# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៤ ខែមីនា លេខ ៣

ព.ស. ២៤៩៤ — គ.ស. ១៩៥២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|


| | | |
|---|---|---|
| ពន្លឺអាស៊ីទ្វីប (តមក) ........... | លោកវ៉ាយ - ប៊ុក .......... | ១៦៣ |
| លោកិយលោកុត្តរបញ្ញាកថា ........ | ព្រះអាចារ្យ ទូច - យ៉ុង ...... | ១៧០ |
| អត្ថានុទិដ្ឋិ .................. | ឧកញ៉ា សំ - ស៊ុន ........ | ១៧៦ |
| កម្មវិភាគ .................. | ព្រះមហា ឧម - ឆាគ្រី ...... | ១៨២ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| ល្បើកក្រើនជាតិ .............. | លោក ប៊ូ - ប៉ូ .......... | ១៨៦ |
| ការបណ្ដុះនិស្ស័យ (តមក) ........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម ... | ១៨៩ |
| រឿងសាមកុក (តមក) ........... | ឧកញ៉ា ទូ - កន .......... | ១៩៦ |
| រឿងអារក្សថ្លែងរឿងខ្មែប្រាំ (តមក) .... | លោក សាង - សាវ៉ាត ....... | ២០៤ |
| រឿងស្នេហាជាតិ (តមក) ........... | លោក គង់ - លឹម.......... | ២១០ |
| រឿងប៉ូលនឹងវីរ៍ស៊ីនី .............. | សាស្ត្រាចារ្យ ផេង - ជ្រីវ ..... | ២២០ |
| សំលៀកបំពាក់ខ្មែរ .............. | ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ..... | ២២៤ |
| **កំណត់នឹងប្រវត្តិការណ៍** | | |
| ពិធីបុណ្យកឋិន នៅវិទ្យាល័យស៊ីសុវត្ថិភ្នំពេញ | ក្រុមសាស្ត្រាចារ្យនឹងក្រុមសិស្ស.. | ២៣១ |


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨៣រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE


| | | Pages |
|---|---|---|
| La lumière de l'Asie (suite)...... | *M. Ray-Buc* .......... | 163 |
| Lokiyalokuttarapannâkathâ ..... | *Vén. Touch-Long* ........ | 170 |
| Attânuditthi ............... | *Oknha Sam-Sun* ........ | 176 |
| Kammavibhaga............... | *Vénérable Om-Nakry* ...... | 182 |


### PARTIE LITTERAIRE


| | | |
|---|---|---|
| Conseil d'après l'alphabet khmer (Poême)............... | *M. Bou-Po* ............... | 186 |
| Education morale (suite)........ | *Vén. Pœung - Pam* ......... | 189 |
| Histoire de SAMBOK (suite) .... | *Oknha Nou - Kan* ......... | 196 |
| Les vingt cinq récits du Mauvais Génie (suite) ............... | *M. Sang - Savat* .......... | 204 |
| L'Amour de la Patrie (pièces de Théâtre).................. | *M. Kong-Lim* ........... | 210 |
| Paul & Virginie (Traduction)... | *M. Phéng-Chrieu* .......... | 220 |
| Les vêtements Camdodgiens ..... | *Commission des Mœurs et Coutumes* | 224 |


### NOTES ET CHRONIQUES


| | | |
|---|---|---|
| Compte - rendu de la fête des offrandes au Lycée Sisowath....... | *Groupe de professeurs et étudiants* | 231 |


Prix d'abonnement annuel (12 numéros: ) 183$00

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៨

**La Lumière de l'Asie**

លោកស៊ើរ-អេតវីង អារណុលត៍ តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

គម្ពីរសំដែងថា មុននឹងកើតវត្ថុទាំងអស់ ដំបូងមានអន្ធកាព (Ténèpres) នឹងព្រះព្រហ្មពិចារណា ម្នាក់ឯងក្នុងពេលយប់; កុំឲ្យពិនិត្យនូវព្រះព្រហ្ម ឬបុព្វហេតុនៃលោក! ចក្ខុសាមញ្ញសត្វមិនអាចមើលឃើញនូវព្រះព្រហ្ម ឬវស្សីអ្វីឡើយ ព្រោះថាសាមញ្ញសត្វមិនអាចដឹងយល់នូវវត្ថុខាងលើនេះបាន; ផ្ទាំងផងឹតនោះនឹងរបើកតាមលំដាប់តគ្នាម្ដងមួយៗ តែត្រូវមានផ្ទាំងផងឹតឯទៀត ចូលមកស្ថិតនៅតាមលំដាប់មុនក្រោយតទៅទៀត ៗ តារាគោចរមុខក្រោយ តាមច្បាប់ក្បួនតារាសាស្ត្រ តែមិនអាចសួរឆ្លើយឆ្លងគ្នាបាន ៗ គ្រាន់តែមានជីវភាពនឹងមរណភាព, សុខនឹងទុក្ខស្ថិតនៅព្រមទាំងហេតុផល, កាលវេលា, នឹងទឹកជោរនាច នៃលំនាំជីវិតសត្វដែលប្រែប្រួលជានិរន្តរកាល, ប្រៀបដូចជាស្ទឹងមួយ ដែលមានរលកបោកបក់តាមលំដាប់, ហូរឃើត ឬ ឆាប់មានសភាពដូចគ្នាពិតមែន, តែខុសគ្នា, តាំងពីប្រភពឆ្ងាយរហូតដល់សមុទ្រជាបរិយោសាន ៗ

បំណែកសមុទ្រនោះ មានទឹកដែលព្រះអាទិត្យស្រូបយកទៅផ្លាស់ប្តូរ ទឹករលកនោះសាបសូន្យ ប្រែទម្រង់ជាពពកដែលរសាត់ទៅប៉ះលើកំពូលភ្នំក្លាយទៅជាទឹកហូរច្ចីតាមលំដាប់ គ្មានពេលទំនេរតទៅទៀត ៗ ឧទាហរណ៍ប៉ុណ្ណោះ, នាំឲ្យយល់នូវសភាពកាន់ច្បាំ, ចំពោះមេឃផែនដីពិភពលោកនឹងការប្រែប្រួល ដែលនាំឲ្យប្រែស្ថានភាពនៃវត្ថុខាងលើ, ទុកជាគង់មានអានុភាពអាចវិលមានការតស៊ូ ទីងកម្លាំងជាជំនួយមិនមានបុគ្គលណាអាចបញ្ឈប់ ឬធ្វើឲ្យមានន័យផ្ទុយចំពោះទីងការចលនានោះបានឡើយ ៗ កុំឲ្យអ្នកបន់ស្រន់អ្វីឡើយ អន្តការមិនអាចក្តីបាន កុំឲ្យអ្នកធ្វើទុក្ខចំពោះចិត្តអ្នកដែលមានទុក្ខស្ថិតនៅស្រាប់ហើយ ! ឱបងប្រុស, បងស្រីអើយ ! សូមអ្នកកុំឲ្យរង់ចាំនូវសាវកនៃព្រះអាទិទេពដែលគ្មានអាណិតអាសូរអ្នកឡើយ ដោយអាមិសបូជា ឬសូត្រធម៌ កុំឲ្យអ្នកធ្វើឲ្យលោកទាំងនោះពេញចិត្តនឹងអ្នក ដោយធ្វើពលិកម្មមានពិឃាតសត្វបូជា កុំអ្នកបូជាផ្លែឈើ ឬនំចំណី គឺក្នុងពួកយើងនេះឯងដែលត្រូវស្វែងរកនូវមធ្យោបាយដែលជាហេតុឲ្យយើងបានចេញចាកវដ្តសង្សារ; មនុស្សម្នាក់ៗ បង្កើតគុកសម្រាប់ដាក់ខ្លួនៗឯង, បុគ្គលម្នាក់ៗ មានអំណាចស្មើនឹងអ្នកដែលមានឫទ្ធានុភាព; ព្រោះថាចំពោះអគ្គបុគ្គលទាំងអស់ ដែលស្ថិតនៅពីលើយើង ឬជុំវិញយើងដូចជាពួកសត្វនិករ ឬជីវសត្វ, គឺកិរិយាប្រព្រឹត្តិនោះឯង ជាហេតុឲ្យសុខទុក្ខ ៗ អតីតហេតុនាំមកនូវ

បច្ចុប្បន្នហេតុនឹងអនាគតៈជាតុ · បាបបុណ្យ ប្រព្រឹត្តក្រោយសម្រាប់អ្នកមុនៗ សម្រាប់អ្នកក្រោយ; សូម្បីតែពួកទេវតានៅស្ថានសួគ៌ក៏ប្រែតកាត់នូវផលនៃអតីតជាតិ; ពួកអារក្សស្ថិតនៅក្នុងហិនភាព, ស្តាយនូវទោសនៃបាបអកុសលដែលខ្លួនបានប្រព្រឹត្តពីកាលមុន; គ្មានអ្វីស្ថិតស្ថេរក្នុងលោកទេ គុណធម៌ក៏ធ្លាក់វិនាសសាបសូន្យជាមួយនឹងកាល, បាបអកុសលអាចប្រែកែឲ្យបានបរិសុទ្ធស្អាតទៅវិញ ។ អ្នកណាដែលរស់នៅលំបាកក្នុងឋានៈ ជាទាសកម្មករអាចដល់អនាគតជាតិទៅចាប់បដិសន្ធិជាព្រះអង្គម្ចាស់ ដោយមានគុណធម៌នឹងបុណ្យកុសលដែលបានបំពេញ; អ្នកដែលពីដើមជាព្រះមហាក្សត្រត្រឡប់ទៅជាត្រាច់រង្គាត់ នៅលើផែនដីជាពួកទុគ៌តពាក់ខោអាវកណ្ដាចនោះគឺ ដោយហេតុបាបដែលខ្លួនប្រព្រឹត្តនឹងបុណ្យដែលខ្លួនក្លួចធ្វើ ។ អ្នកអាចដំកើងជោគវាសនាអ្នកនោះស្មើនឹងសត្វដន្ទេន ឬ កំទេចបរមាណូ; មានជីវសត្វជាច្រើនលានអាចធ្វើដំណើរទៅដល់លទ្ធផលទីមួយ, ខ្លះទៀតបានលទ្ធផលទីពីរ ។ ដរាបណាកង់ចក្រដែលយើងមើលមិនឃើញនៅតែវិល, ដរាបនោះគ្មានសន្តិសុខទេ, គ្មានពេលសម្រាក, គ្មានពេលឈប់ឈរទេ អ្នកណាដែលឡើង អាចធ្លាក់; អ្នកណាដែលធ្លាក់ អាចឡើងវិញ; កាំកង់នោះវិលគ្មានទំនេរ ។

បើខ្លួនអ្នកគេចង ភ្ជាប់នូវកង់ដែល មានសភាពប្រែប្រួលដោយគ្មានមធ្យោបាយអ្វីធ្វើឲ្យបាក់បែកនូវបំណងកង់នោះ, ហទយវត្ថុនឹងជីវសត្វសេរី

គួរឲ្យក្តៅចិត្តពន់ពេក, វិញ្ញាណនៃវត្ថុទាំងឡាយមុខជានឹងរងទុក្ខលំបាក ឥតល្ហែ ៗ តែអ្នកមិនមែនគេបង្ខាប់ទេ! វិញ្ញាណនៃវត្ថុទាំងអស់មានសភាពស្លូតត្រង់, ចិត្តនៃសត្វនិករប្រកបដោយសន្តិភាព, ឆន្ទៈមានអានុ-ភាពជាងទុក្ខ; អ្វីដែលល្អទៅជាសោភាវិសេសតាមលំដាប់ ៗ តថាគត, ព្រះពុទ្ធដែលបានអាណិតអាសូរដល់បងប្អូនទាំងអស់គ្នា ដែលចិត្តជាប់ជំពាក់នឹងសេចក្តីទុក្ខ ក្នុងលោកភព តថាគតសើចហើយសប្បាយផង ព្រោះតថាគតបានឃើញផ្លូវដែលនាំទៅកាន់សេរីភាពហើយ, ឱអ្នកដែលមានទុក្ខ! ចូរអ្នកជ្រាបថាទុក្ខនោះមកពីអ្នកឯង ៗ គ្មានអ្នកណាបង្ខំផ្សេងពីអ្នកឯងបញ្ឈោរអ្នក ឬបង្ខំអ្នកឯងដើម្បីឲ្យអ្នកកើតរួចស្លាប់វិញ ហើយធ្វើឲ្យអ្នកវិលជាមួយនឹងកង់ហើយថ្ងូរងំទៅលើកាំកង់នោះឡើយ, យំទួញសោកនៅលើខ្នងកង់ហើយ បង្វិលជុំនោះទៅរកសភាពសាបសូន្យទទេ ៗ ចូរអ្នកស្តាប់តថាគតៗនឹងបង្ហាញអ្នកអំពីអរិយសច្ចៈ នៅក្រោមៈស្ថាននរក, នៅខាងលើៈស្ថានសួគ៌, នៅឆ្ងាយជាងតារានោះទៅទៀត ឆ្ងាយសែនឆ្ងាយ, ម្ខាងស្ថានព្រហ្ម, មានអានុភាពមួយជាបវរន្ត, ឧត្តមផុតអស្ចារ្យដែលស្ថិតនៅមុនបុព្វហេតុ ហើយគ្មានអវសានហេតុ, ប្រកបដោយអនន្តកាលដូចមហាមេឃហើយពិតដូចជាសច្ចធម៌ ដែលវិលទៅរកសោភណភាពហើយប្រព្រឹត្តទៅតាមបទបញ្ញត្តិខ្លួន ៗ អានុភាពនោះធ្វើឲ្យកុឡាបមានផ្កា, គឺសិល្បៈនៃអានុភាពនោះដែលរចនាសិល្បៈនៃស្លឹក

ប់ទុម; នៅក្រោមព្រះធរណីងងឹតហើយក្នុងតូចដែលសាបព្រោះ ដោយស្ងាត់ស្ងប់, អានុភាពនោះរចនាធម្មជាតិស្រស់ស្រាយនៃនិទាឃៈរដូវ, នេះជាពណ៌នៃអានុភាពនោះ ស្ថិតនៅក្នុងពពកទឹងពណ៌មកិតស្ថិតនៅលើកន្ទុយក្អែក, ពួកតាកជាប្រាសាទនៃអានុភាពនោះ, រស្មី, ខ្យល់; ភ្លៀងជាអ្នកបម្រើ, អានុភាពនោះបញ្ចេញពីអន្តភាពនូវចិត្តមនុស្សទាំងអស់ ហើយបញ្ចេញពីពងងងឹត. នូវមាន់ទោ មានករំលេចពណ៌ជាច្រើនយ៉ាង; អានុភាពនោះចេះតែបំពេញករណីយកិច្ចឥតមានស្រាកស្រាន, ហើយធ្វើឲ្យស្រឡាញ់, ធ្វើសភាពដែលស្អប់ឲ្យវិនាស ៗ ពងប្រផេះ នៅក្នុងសំបុកសត្វប្រចៀវមានសុវណ្ណពណ៌នេះ ជារតនវត្ថុរបស់ព្រះអង្គ, រន្ធសំបុកឃ្មុំជាព្រះសុវណ្ណកិង្គានៃព្រះអង្គ, ស្រមោចប្រតិបត្តិតាមព្រះឱវាទហើយព្រាបញ្ញើសស្តាប់ព្រះរាជឱង្ការ ៗ ព្រះអង្គទ្រង់ធ្វើស្លាបបក្សាខ្វង់ឲ្យត្រដាងហើរទៅនាំចំណីមកឲ្យកូនបរិភោគ ឯសំបុក, ទ្រង់នាំបំបកញីឲ្យទៅនៅជិតកូនវា, ទ្រង់ស្វែងរកចំណីមកឲ្យសត្វទិករ ទឹងមិត្រភាពមកកាន់សត្វដែលគ្មានអ្នកណាស្រឡាញ់ ៗ គ្មានអ្វីដែលធ្វើឲ្យព្រះអង្គទ្រង់ស្អប់ខ្ពើម ឬជំទាស់ទឹងបំណងព្រះអង្គឡើយ; ព្រះអង្គទ្រង់ស្រឡាញ់ទាំងអស់, ទ្រង់យកទឹកដោះទៅប្រតិស្ឋានក្នុងដោះនៃមាតាទាំងឡាយ, តែទ្រង់យកពិសសទៅដាក់នឹងចង្កូមពស់ ៗ ទ្រង់បានធ្វើស្ថានទាំងអស់ឲ្យមានរបៀបរៀបរយ, ស្ថានដែលវិលនៅលើ

និកាល័យ, ហើយទ្រង់បានលាក់បំពួនក្នុងប្រថពី នូវមាស, ត្បូងប្រផេះក្រហម, ត្បូងខៀវ, ត្បូងខៀវផ្ទៃមេឃ ។ បញ្ចេញនូវវិទ្យាដ៏ស្ងាត់សុខុម, ទ្រង់នៅសម្ងំពួនក្នុងព្រៃមានពណ៌ខៀវស្រងាត់ ហើយ ប្រគល់ជីវិតទៅរុក្ខាដែលដុះនៅគល់ដើមសេដ្រ (Cèdres) មានស្លឹក, ផ្កាព្រមទាំងតិណ-ជាតិ ៗ ទ្រង់សម្ងាប់ហើយ ស្រោចស្រង់មិនមានបំណងក្រៅពីឲ្យវត្ថុទាំងនោះសម្រេចទៅតាមជោគវាសនាសត្វ ៗ ខ្លួនទេ, មរណៈទីងទុក្ខគឺជាគល់នៃគ្រឿងតម្បាញរបស់ព្រះអង្គ, ព្រហ្មវិហារទីងជីវភាពគឺជាអំបោះ ៗ អានុភាពនេះ ធ្វើ ឬធ្វើជាថ្មី, កែប្រែទាំងអស់, ដែលអានុ-ភាពនោះធ្វើក្នុងបច្ចុប្បន្នគឺវិសេសជាងដែលព្រះអង្គធ្វើពីអតីតកាល, ស្នាព្រះហស្តដែលព្រះអង្គធ្វើកំចំរើនតាមលំដាប់ ៗ នេះគឺករណីយកិច្ចរបស់ព្រះអង្គ បំពេញទៅលើវត្ថុទាំងអស់ដែលអ្នកឃើញគ្រប់គ្នា, តែវត្ថុដែលមិនឃើញមានសារប្រយោជន៍ជាងគឺ ចិត្ត, ប្រាជ្ញារបស់មនុស្ស, ចិន្តានៃប្រជាពស្ត្រ ផ្លូវដែលប្រជាពស្ត្រត្រូវត្រាច់, ឆន្ទៈរបស់ប្រជាពស្ត្រសុទ្ធតែនៅក្រោមបង្គាប់បញ្ជានៃបទបញ្ញត្តិដ៏ឧត្តមនេះ ៗ មើលមិនឃើញតែអានុភាពនោះឧបត្ថម្ភដោយព្រះមហាករុណាធិគុណ, គេស្ដាប់មិនឮតែអានុភាពនោះពោលខ្លាំងដូចព្យុះសង្ឃរា ៗ មេត្តាករុណា គឺជាចរិយារបស់មនុស្សល្អ ព្រោះប្រជាករដែលខ្វាក់ងងឹតតែងងប់ក្នុងអំពើកាចសា-ហាវ, អ្នកដែលមិនព្រមធ្វើតាមលោកតែងខាត, អ្នកដែលព្រមធ្វើតាម

លោកតែងចំណេញ, លោកចែកបុណ្យដែលស្ថិតនៅក្នុងសន្តិសុខ និងសុខភាព, បាបអកុសល នៅក្នុងទុក្ខ ។ លោកឃើញទាំងអស់គ្រប់កន្លែង, និគមជនបទ, ប្រែកលក, ហើយលោកពិនិត្យទាំងអស់គ្មានសល់, បើអ្នកសុចរិត អ្នកនឹងបានទទួលរង្វាន់, បើអ្នកទុច្ចរិត អ្នកនឹងបានទទួលនូវផលដ៏លាមកនោះមិនខាន, បើសិនណាជាព្រះធម៌ បន្ទង់មិនបានឲ្យផលភ្លាមៗ ។ លោកមិនស្គាល់ទោសៈ ឬខន្តីចំពោះទោសៈ, វិធានរបស់លោកត្រឹមត្រូវទាន់ពេក, តុល្យភាពថ្លឹងស្មើឥតខ្ចោះ កាលគ្មានចំពោះលោកៗ សម្រេចសេចក្តីស្អែកឬកាលក្រោយក៏បាន ។ ហេតុទាំងអស់មកពីព្រះអង្គ, អ្នកពេជ្ឈឃាតធ្វើឲ្យខ្លួនរបួសនឹងកាំបិតរបស់ខ្លួន, ចៅក្រមទុច្ចរិតគ្មានអ្នកណាការពារ, អណ្តាតបោកបញ្ឆោតគេធ្វើឲ្យឃើញកុហក, ចោរនឹងអ្នកកំហែងប្រគល់ផលិតកម្មដែលបានមកពីការលួចប្លន់ឬប្រព្រឹត្តលាមក ។ នេះជាបញ្ញត្តិដែលមានចលនាទៅតាមយុត្តិធម៌ដែលបុគ្គលណាមិនអាចកំផែក ឬ បញ្ឈប់បាន, ចិត្តព្រះអង្គជារូបព្រហ្មវិហារ, គំនិតជាអវសានរបស់ព្រះអង្គជាសន្តិភាព ឬសុក្រិតភាពត្រូវតែប្រតិបត្តិតាមខានមិនបាន !

(មានត)

# លោកិយលោកុត្តរបញ្ញាកថា

## ព្រះអាចារ្យ ទូប-ទៀង វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ

ទេសនាផ្សាយតាមវិទ្យុឃោសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើតខែពិសាខ
ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (៦-៣-៤៨)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខ្ញុំព្រះករុណា សូមនមស្សការ ចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្ដីគោរព ។

នត្ថិ បញ្ញាសមា អាភា
ពន្លឺស្មើដោយបញ្ញា មិនមាន ។

បណ្ដាពន្លឺទាំងឡាយក្នុងលោក មានពន្លឺព្រះអាទិត្យ ព្រះចន្ទជាដើមនេះ គ្រាន់តែសម្រាប់បំភ្លឺក្នុងកមហាជនទាំងពួង ឲ្យឃើញបានតែត្រឹមរូបផ្សេងៗប៉ុណ្ណោះ នឹងអាចឆ្លុះយល់នូវហេតុនឹងផលនៃសេចក្ដីសុខ-ទុក្ខ ទាំងពួងក្នុងលោកនេះ នឹងលោកខាងមុខពុំបាន ។ ដូចឃើញថា ការប្រព្រឹត្តសុចរិត ជាហេតុនៃសេចក្ដីសុខ, ការប្រព្រឹត្តទុច្ចរិតជាហេតុនៃសេចក្ដីទុក្ខដូច្នេះជាដើម នេះក៏អាស្រ័យដោយពន្លឺពោលគឺបញ្ញានេះឯង ទើបពិចារណាឃើញបាន ។

## ប្រភេទនៃបញ្ញាមាន ២ យ៉ាង គឺ:

១ – លោកិយបញ្ញា បញ្ញាសម្រាប់ប្រើការក្នុងលោកនេះ នៃជនជាបុថុជ្ជន ។

២ – លោកុត្តរបញ្ញា បញ្ញាសម្រាប់ពិចារណា នូវមគ្គនិងផល ដើម្បីចូលទៅកាន់ព្រះនិព្វាន នៃព្រះអរិយបុគ្គលជាម្ចាស់ ។

បញ្ញាឈ្មោះថាពន្លឺភ្លឺស្វាងរុងរឿង ជាងពន្លឺដែលមាននៅក្នុងលោកនេះទាំងមូល ។ ឯក្នុងលោកនេះទាំងមូល ហេតុជារបស់សំខាន់បំផុត បើបុគ្គលអ្នកស្គាល់នូវ "ហេតុ" បាន គេទុកជាមនុស្សសំខាន់បំផុត ។ ដូចស្គាល់ច្បាស់ថា: ការនាំឲ្យថោកទាបជាតិកំណើតរបស់ខ្លួន មកពីលង់ខ្លៅជាហេតុ, ការលង់ខ្លៅមកពីគ្មានជម្រេះវិជ្ជាសម្រាប់ផ្លូវលោក ផ្លូវធម៌ជាហេតុ, ការគ្មានជម្រេះវិជ្ជាមកពីការខ្ជិលជាហេតុ ។

ការខ្ជិលច្រអូស ជាមេជាដើមបណ្ដុះបណ្ដាលខាងបាប, សេចក្ដីព្យាយាម ជាមេបណ្ដុះបណ្ដាលខាងបុណ្យ ឲ្យចំរើនសព្វប្រការ ។

ឯជម្រេះវិជ្ជានិងភោគសម្បទ ជាហេតុបណ្ដុះបណ្ដាលឲ្យសម្រេចប្រយោជន៍បានច្រើនប្រការណាស់ ដូចក្នុងប្រទេសជាតិនិមួយ ៗ ដែលមានសេចក្ដីចំរើនសុខដ៏ធំទូលាយ ឡើងទៅកាន់ថ្នាក់ជាន់លើខ្ពស់ត្រដែតគ្រប់ដំបាននៅបាននោះ ព្រោះមានជម្រេះវិជ្ជាជាហេតុផង មានភោគសម្បទជាហេតុផង ។

កុសលធម៌ ឃើញដូចព្រះបរមគ្រូរបស់យើង ដែលព្រះអង្គទ្រង់បំពេញព្រះបារមីមក ក៏អាស្រ័យភោគសម្បទជាហេតុ ដូចកាលទ្រង់បំពេញ ទាន, សីល, នេក្ខម, បញ្ញា, វីរិយ, ខន្តិ, សច្ច, អធិដ្ឋាន, មេត្តា, ឧបេក្ខា; នេះអាស្រ័យភោគសម្បទ ជាកំលាំង ជាគ្រឿងទំនុកបម្រុងដល់បារមីធម៌ទាំង ១០ ប្រការ ឲ្យបានត្រាស់ដឹងជាព្រះពុទ្ធនេះឯង ។

ចំណែកសាវក-សាវិកាទាំងឡាយរបស់ព្រះអង្គ ក៏អាស្រ័យកំឡាំងភោគសម្បទ ជាហេតុដូចគ្នា តួយ៉ាងដូចអគ្គសាវកទាំងគូរបស់ព្រះអង្គ គឺព្រះមហាសារីបុត្តត្ថេរ កាលកើតជាសរទតាបសក្តី ព្រះមហាមោគ្គល្លានត្ថេរ កាលកើតជាសិរិវឌ្ឍកុដុម្ពិកៈក្តី លោកទាំងពីរនេះសុទ្ធតែមានភោគសម្បទ មានខ្ញុំច្រើនរាប់ម៉ឺនអស់ បានបំណាយឲ្យទានកសាងបុណ្យ កសាងកុសលច្រើនប្រការណាស់ បានតាំងប្រាថ្នាជាអគ្គសាវករបស់ព្រះអង្គ មកបានសម្រេចដូចសេចក្តីប្រាថ្នា ក៏ឃើញថាអាស្រ័យភោគសម្បទជាហេតុ ឲ្យបំពេញសាវកបារមីញាណដែរ ។

ព្រះអរិយសាវករបស់ព្រះអង្គឈ្មោះអនាថបិណ្ឌិកក្តី ព្រះអរិយសាវិកាឈ្មោះវិសាខាមហាឧបាសិកាក្តី លោកទាំងនេះសុទ្ធតែមានភោគសម្បទស្តុកស្តម្ភមាំមួនណាស់ ទាល់តែល្បីពេញក្នុងលោក ក៏អាស្រ័យភោគសម្បទជាហេតុ ឲ្យមានឧបនិស្ស័យនៃសោតាបត្តិមគ្គ ឲ្យថ្លៃថ្លាខ្ពង់ខ្ពស់រាល់ជាតិដរាបដល់ទីបំផុត នៃលោកុត្តរសម្បត្តិយ៉ាងនេះ ក៏អាស្រ័យកំលាំងភោគសម្បទជាហេតុដូចគ្នា ។

មនុស្សជាតិម្នាក់ៗ ដែលបានកើតមកជាមនុស្សហើយ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ត្រូវដម្កល់ខ្លួនតាមវ័យរបស់ខ្លួន ទើបចំរើនជាសុខបាន ។

បុគ្គលឯណាដម្កល់ខ្លួនឯងមិនត្រូវតាមវ័យរបស់ខ្លួន បុគ្គលនោះមុខជាបានទុក្ខយ៉ាងធ្ងន់ ៗ ឯវ័យនោះមាន ៣ បើតាមគម្ពីរវិសុទ្ធិមគ្គត្រង់បញ្ញានិទ្ទេសព្រះពុទ្ធឃោសាចារ្យ លោកកំណត់យកតាមអាយុរបស់មនុស្សចំនួន ១០០ ឆ្នាំ មកបែងជា ៣ ជាន់ គឺជំនាន់ដំបូងកំណត់តាំងពីឆ្នាំដែលកើតរៀងទៅដល់អាយុ ៣៣ ឆ្នាំ ហៅថា "បឋមវ័យ" វ័យជាដំបូងនេះ ត្រូវស្វះស្វែងរករៀនជម្រះវិជ្ជាឲ្យចេះដឹងអក្សរសាស្ត្រសម្រាប់កត់ត្រាផ្សេងៗ ឲ្យចេះភាសាសាស្ត្រ សម្រាប់និយាយដោះស្រាយការផ្សេងៗ ធ្វើយធ្លងទាក់ទងទៅវិញទៅមកគ្នានៃមនុស្សជាតិផ្សេងៗ ឲ្យចេះលេខ-គណិតទួន សម្រាប់គិតគូរពក់ព្រៀកការងារទាំងពួង, ឲ្យចេះជញ្ជីងនាឡិ-ហាប រង្វាស់រង្វាល់ជាដើម សម្រាប់លក់ដូរដូរប្រែកែខែចំណូលចំណាយឲ្យចេះស្ទាត់ជំនាញក្នុងបឋមវ័យនេះ ។

ជំនាន់ទីពីរតាំងពីអាយុ ៣៤ ឆ្នាំ រៀងទៅដល់អាយុ ៦៧ ឆ្នាំ ហៅថា "មជ្ឈិមវ័យ" គឺវ័យតាំងនៅជាកណ្ដាលនេះ ជាវ័យត្រូវយកជម្រះវិជ្ជារបស់ខ្លួននោះ មកតាំងព្យាយាមចំប្រឹងខ្នះខ្នែងស្វែងរកភោគសម្បត្តិដោយជំនួញដូរប្រែ តាមផ្លូវទឹក-ផ្លូវគោក សន្សំទុកដាក់ទ្រព្យសម្បត្តិ

មាននៅកុះករឡើង ឬ នឹងពង្រីកទ្រព្យសម្បត្តិដែលរកបាននោះ ឲ្យមានប្រយោជន៍ធំទូលាយតទៅ ។

ជំនាន់ទី ៣ គឺកំណត់តាំងពីអាយុ ៦៨ រៀងទៅដល់អាយុ ១០០ ឆ្នាំ ហៅថាបច្ឆិមវ័យ" គឺវ័យតាំងនៅទីបំផុត វ័យនេះមិនមែនជាវ័យត្រូវរកត្រូវរៀនទេ ប្រាកដជាវ័យត្រូវទទួលផលជាសុខគ្រប់ប្រការ អំពីគុណជាម្រែះវិជ្ជានឹងផលនៃភោគសម្បទ ។

កាលបើបុគ្គលដាក់ខ្លួនមិនត្រូវតាមវ័យ បឋមវ័យជាវ័យត្រូវរៀនសូត្រជាម្រែះវិជ្ជា ត្រឡប់ទៅជាតាំងខ្លួនស៊ីផឹក ដើរលេងល្បែងផ្តេសផ្តាស ទាល់តែខ្លួនកន្លងផុតបឋមវ័យនេះទៅ ខ្លួនក៏ធ្លាក់ចុះទៅក្នុងកណ្តាប់ដៃល្ងង់ខ្លៅ ។

កាលតាំងនៅក្នុងមជ្ឈិមវ័យ គឺជាវ័យត្រូវរកភោគសម្បទ ត្រឡប់ជាស្ទះស្ទើររករៀនជាម្រែះវិជ្ជាវិញ ធ្វើម្តេចនឹងបានទាន់ពេលសម័យយកវិជ្ជាការនោះ មកប្រើការបានដូចបំណង ឬ ជាវវល់ប្រព្រឹត្តលេងអបាយមុខដែលជាគ្រឿងនាំមកនូវសេចក្តីវិនាស, គឺជាអ្នកវវល់នឹងលេងស្រី ជាអ្នកវវល់លេងស៊ីផឹកៗស្រា ជក់អាភៀន គ្រឿងញៀន-គ្រឿងស្រវឹង, ជាអ្នកវវល់លេងល្បែងស៊ី-សង ។ ជាអ្នកវវល់ដើរលេងជាមួយនឹងមនុស្សពាល-អាក្រក់ យកមកជាមិត្តរបស់ខ្លួន ។ គ្មានបានឳកាសរកទ្រព្យសម្បត្តិអ្វីសោះ ទាល់តែខ្លួនកន្លងផុតមជ្ឈិមវ័យនេះទៅ ក៏ធ្លាក់ចុះទៅកណ្តាប់ដៃនៃសេចក្តីក្របេហមរហាមកើតទុក្ខវេទនាជាទីបំផុត ។

កាលតាំងនៅក្នុងបច្ឆិមវ័យ ជាវ័យត្រូវបុគ្គលទទួលផល គឺសេចក្តីសុខគ្រប់យ៉ាង ៗ ឯបុគ្គលខ្ជិលបានសេចក្តីសុខអំពីណា ព្រោះវល់តែដេកថ្ងូរអំពីល្ងង់ នឹងសេចក្តីទីទ័លក្រដពាបដល់ស្លាប់ប៉ុណ្ណោះ ៗ

បុគ្គលសេពគប់ជនពាល រមែងលិចចុះក្នុងសេចក្តីវិនាសក្នុងលោកនេះនឹងលោកខាងមុខ ៗ បុគ្គលសេពគប់ជនជាបណ្ឌិត រមែងដល់នូវសេចក្តីចំរើនក្នុងលោកនេះ នឹងលោកខាងមុខជាប្រាកដ ៗ ដូចបានសំដែងមកហើយពីខាងលើនេះ សូមឲ្យពុទ្ធបរិស័ទនឹងយុវជន-យុវនារីរួមជាតិទាំងឡាយ ស្ទុះក្រោកឡើងចាកសេចក្តីខ្ជិល ចូរខំតាំងខ្លួនរៀបខ្លួនប្រកបកិច្ច ឲ្យត្រូវតាមលំដាប់វ័យ ដែលបានសំដែងមកនេះចុះ ទើបអ្នកនឹងបានចំរើនក្នុងលោកនេះ នឹងលោកខាងមុខជាប្រាកដមិនខាន ៗ

ធម៌ទេសនាចប់ប៉ុណ្ណោះ

## សប្បុរិសានំ សុភំ ហោតុ វឌ្ឍន្តុ សព្វេបិ ពុទ្ធសាសនេ

សូមសេចក្តីល្អគ្រប់យ៉ាង ចូរមានដល់អស់លោក-អ្នកសប្បុរសទាំង-ឡាយគ្រប់ពេលវេលាកុំបីចន្លោះ សូមឲ្យពួកពុទ្ធបរិស័ទគ្រហស្ថ-បព្វជិតទាំងអស់ ចំរើនសុខសួស្តីជយមង្គលក្នុងព្រះពុទ្ធសាសនាទៅហោង ៗ

ចប់

# អត្តានុទិដ្ឋ

## អ្នកឧកញ៉ាឥស្សរវង្ស សំ-ស៊ុន

ជាអ្នកប្រែរៀបរៀង

---

រឿងនេះជារឿងចំឡែក  គួរពុទ្ធមាមកៈត្រិះរិះពិចារណាដោយប្រាជ្ញាឲ្យបរិបូណ៌ចុះ  ព្រោះអ្នកសិក្សាផ្លូវព្រះពុទ្ធសាសនា  ដោយភាគច្រើនប្រកាន់យកតែត្រង់អនត្តា  ឯអត្តាវិញ  ច្រើនតែថាគ្មានគុណទីទាំងពួង  ព្រោះអាស្រ័យហេតុនេះ  ទើបខ្ញុំយករឿងអត្តាមកអធិប្បាយជូនស្តាប់  ប្រែចេញពីសៀវភៅសៀមឈ្មោះថេរបញ្ញត្តិ  ទំព័រលេខ ២៨ ។

អត្តានុទិដ្ឋិ  ពាក្យនេះប្រែថា "សេចក្តីឃើញថាអត្តាមាន" សំគាល់យកសេចក្តីយល់ឃើញក្នុងខន្ធ ៥ ដែលជាសំខតធម៌ថាជាខ្លួនប្រាណ  គឺខន្ធ ៥ ទុកជាអត្តា  ជាខ្លួនប្រាណយើងនេះ;  តាមយល់ឃើញនេះ  ចាត់ជាសេចក្តីឃើញក្រៅអំពីអរិយសច្ចធម៌របស់ព្រះសម្មាសម្ពុទ្ធ ។ តែសេចក្តីចូលចិត្តរបស់អ្នកដឹងភាគធំក្នុងផ្លូវព្រះនិព្វាន  ឃើញថាយើងឬខ្លួននោះមិនមានគុណទីទាំងពួង  ហើយទាញយកសេចក្តីទីងពាក្យផ្សេងៗ  តាមដែលបានជួបប្រទះជួបពាក្យថាអនត្តា  ដែលប្រែថា "មិនមែនខ្លួន"  នោះទុកជាឡាក់ឋាន  ទាំងជឿតាមគ្នាខ្លះ  ថែមទាំងដំកជាច្រើនក៏សំដែងចេញជាល្ហល្ហាចទៅផង  សឹងតែជាប់ដោយសេចក្តីឃើញឆ្វេងនោះឯង ។  តាមដែលបានសង្កេតមក  រឿងនេះ  ជាផ្លូវកាចសាហាវដ៏ខ្លាំង

បើអ្នកឯណាយល់ឃើញថាយើងមាន ខ្លួនមាន អ្នកនោះទឹងត្រូវជាអ្នកបណ្ដុះទិដ្ឋិយ៉ាងនោះតែម្យ៉ាង ជាប់ការសមាគមគប់រកគ្នា ព្រោះសេចក្ដីយល់ឃើញបែកគ្នា ឲ្យទទួលធាយាជាមិច្ឆាទិដ្ឋិក្រៅព្រះសាសនា, អាស្រ័យហេតុនេះ ទើបត្រូវតែនិយាយទៅតាមគ្នាថា "យើងមិនមាន ខ្លួនមិនមាន" ។

ក៏ក្នុងសៀវភៅច្បាប់នេះ បានប្រកាសសេចក្ដីយល់ឃើញថា "យើងមាន ខ្លួនមាន" ដូចនិយាយថា "កាលបានសេចក្ដីបរិសុទ្ធិជាវិកគធម៌ហើយ ក៏រាប់ថាបានយើង ឬ អត្តា (ខ្លួនប្រាណ) ដែលពិតប្រាកដ", ដូច្នេះមិនត្រូវគេតិះដៀលថាទត្តិ បញ្ញត្តិយើង ឬ អត្តាហើយឬ? ព្រោះគេតែងនិយាយប្រដៅគ្នាថា ឲ្យដកយើង ដកខ្លួនចេញ កុំធ្វើសេចក្ដីចូលចិត្តថា "យើងមាន ខ្លួនមាន" ទើបចាត់ថាឃើញត្រូវត្រង់ពិតៗ, សូម្បីតែព្រះនិព្វានដែលជាវិសង្ខារក៏ថាយើង ឬ អត្តាមិនបាន ប្រែថា មិនមានកងទីតាំងតួង ។

ក៏សេចក្ដីឃើញថា ខ្លួនមិនមាននោះ តើទុកជាត្រូវដូចម្ដេចកើត បើនិយាយឲ្យអ្នកស្ដាប់ៗ មិនចូលចិត្តសោះ ព្រោះរកអ្វីភាញមកជាគោលមិនបាន និយាយរល់ដូចទឹកក្នុងអាង ស្ដាប់ទៅដូចនិយាយលេងបញ្ឆោតមនុស្សចំពោះមុខ និយាយថា "យើងមិនមាន ខ្លួនមិនមាន" យ៉ាងនេះយ៉ាងនោះហើយ ក៏រត់ពីយើង ឬ រត់ពីខ្លួនទៅមិនផុត ត្រឡប់ចូលមក

រកយើង រកខ្លួនវិញ; សែនទ្ពើមយើង ទ្ពើមខ្លួននេះហើយ តែដល់ទៅពឹងអ្នកណានៅទីណាមិនបាន ក៏ត្រឡប់ចូលមកពឹងយើង ពឹងខ្លួនវិញ នេះជាទិដ្ឋិៗ នេះបើជាមនុស្សវិញ គេថាមនុស្សមិនល្អ; អ្នកទេសន៍តែងសំដែងធម៌ពោលបដិសេធយើង ឬខ្លួនដោយប្រការផ្សេងៗ ៗ យើង ខ្លួន រមែងមិនមានព្រោះហេតុនេះឯង ។ ល្មមតែព្ញើទើបពោលថាយើងទៅបង្កាប់យកឯខ្លួនឯង, ដែលពិត យើង ខ្លួន នោះជាមិនមានទេ មានតែហេតុផ្គុំផ្គាសទាំងនោះ. បើថាយើងថាខ្លួនមិនមានហើយបានយើងពីណា ទៅបង្កាប់យើងឯណា ។ ក្នុងទីបំផុតនៃទេសនាពោលថា "យើងនឹងបានទទួលផលដោយគាប់ចិត្ត ព្រោះសេចក្តីឃើញត្រូវថា យើង ខ្លួន មិនមាននោះ ខ្លួនរមែងសុខសម្រាន្តគ្រប់ទិវាពត្រីកាល" ។ សេចក្តីដែលបានពណ៌នាមកនេះ ហៅសែនពិបាកស្តាប់ ។

មនុស្សខ្លះដើងឆ្លាត អាចទាញយកពុកមាត់អណ្តើកស្នែងទន្សាយមកប្រៀបធៀបឲ្យឃើញថា រកយើងឬខ្លួននោះ ដូចមនុស្សដែលស្វែងរកពុកមាត់អណ្តើកស្នែងទន្សាយ រមែងមិនបានសម្រេចដូចសេចក្តីប្រាថ្នា ។ រឿងនេះមិនមានអ្នកណាប្រកែកតសោះ, ក៏មាត់អណ្តើកធម្មជាតិសាងមកមិនមានពុកមាត់, ក្បាលទន្សាយ ធម្មជាតិសាងមកក៏មិនមានស្នែងដូចគ្នា, ះនោះជាសេចក្តីពិត អ្នកណាៗដែលធ្លាប់

ឃើញមាត់អណ្តើកនឹងក្បាលទន្សាយហើយ ក៏ត្រូវព្រមទទួលថាមិនមានពិតមែន តែថាគ្រាន់តែរកពុកមាត់នៅមាត់អណ្តើក ឬស្នែងនៅក្បាលទន្សាយមិនបានប៉ុណ្ណោះ ម្តេចក៏ប្រញាប់បដិសេធថាពុកមាត់នឹងស្នែងក្នុងទីទាំងពួងមិនមានដែរ? បើពុកមាត់នឹងស្នែងមិនមានពិត ហើយពាក្យបញ្ញត្តិហៅពុកមាត់នឹងស្នែងនោះក៏មិនមានដែរ, តែដែលពិត ពុកមាត់នឹងស្នែងនោះមាន ព្រោះមិនមានតែត្រង់មាត់អណ្តើកនឹងក្បាលទន្សាយប៉ុណ្ណោះ, រកពុកមាត់នៅទីមាត់អណ្តើកមិនបាន ក៏នៅទីមាត់ឆ្មាមាន នៅមាត់យើងឯងក៏មានគរគោក, រកស្នែងនៅទីក្បាលទន្សាយមិនបាន នៅទីក្បាលគោក៏មានស្នែង នៅក្បាលក្របីក៏មានស្នែង; បើសិនជាពុកមាត់មិនមានក្នុងទីទាំងពួងពិតហើយ យើងក៏មិនស្គាល់ពុកមាត់ ធ្វើម្តេចនឹងនិយាយបានថា អណ្តើកមិនមានពុកមាត់ដូច្នេះកើត, បើសិនជាស្នែងមិនមានក្នុងទីទាំងពួងពិតហើយ យើងក៏មិនស្គាល់ស្នែងអ្វី ម្តេចនឹងនិយាយបានថា ទន្សាយមិនមានស្នែងដូច្នេះកើត, ព្រោះតែយើងធ្លាប់ស្គាល់ពុកមាត់នឹងស្នែងមកហើយ ទើបយើងនិយាយចេញមកបានថាពុកមាត់អណ្តើក ស្នែងទន្សាយមិនមាន ៗ ព្រោះដូច្នោះ ពុកមាត់នឹងស្នែង រមែងមានជាប្រាកដ នឹងបដិសេធថាមិនមានក្នុងទីទាំងពួងនោះមិនបាន គ្រាន់តែគន់រកមិនសព្វប៉ុណ្ណោះ ៗ ខនេះដូចម្តេចមិញ? យើងឬអត្តានោះមាននៅជាប្រាកដ ព្រះសម្ពុទ្ធ

ទ្រង់ជួបឃើញ ទ្រង់ស្គាល់ហើយ ទើបត្រាស់ប្រដៅមិនឲ្យប្រកាន់ខ្ជាប់ ក្នុងខន្ធទាំង ៥ ដោយព្រះវាចាដូច្នេះថា "នុ៎ះមិនមែនយើង នុ៎ះមិនមែនរបស់យើង នុ៎ះមិនមែនអត្តា (ខ្លួនប្រាណ) របស់យើងដូច្នេះ ៗ ពាក្យប្រដៅយ៉ាងនេះ គឺព្រះអង្គទ្រង់ប្រដៅយើង ប្រដៅអត្តា (ខ្លួនប្រាណ) នុ៎ះឯង ៗ បើសិនជាយើងមិនមាន ខ្លួនមិនមានហើយ ពាក្យប្រដៅដូច្នោះក៏ឥតប្រយោជន៍ ព្រោះមិនមានយើង មិនមានខ្លួននឹងស្តាប់ ព្រោះដូច្នោះយើងឬខ្លួននោះ ត្រូវមានជាពិតប្រាកដ, តែនឹងស្វែងរកក្នុងខន្ធទាំង ៥ ឬសង្ខតធម៌ឯណា ៗ នោះមិនបានទេ ដូចការរកពុកមាត់នៅទីមាត់អណ្តើក នឹងរកស្នែងនៅទីក្បាលទន្សាយ រមែងមិនបានសម្រេច ដូចសេចក្តីបំណង, ព្រោះសង្ខតធម៌ទាំងឡាយ ជាចំណែកខាងបដិសេធដោយសេចក្តីជារបស់មិនល្អ មានទុកជាសភាពមិនជាវ៉ៈ មិនមែនយើង មិនមែនខ្លួន រមែងត្រូវបានក្នុងព្រះនិព្វាន, ព្រះនិព្វាននោះឯងជាយើង ជាខ្លួន ៗ ដូច្នេះកាលបើបដិសេធសង្ខារដែលជាត្រៃយលោកិយហើយ ក៏ត្រូវទទួលព្រះនិព្វាន ដែលជាត្រៃយលោកុត្តរ ព្រោះខាងមួយល្អ ខាងមួយអាក្រក់ ឬខាងមួយទៀង ខាងមួយមិនទៀង ខាងមួយមិនស្អាត តែម្ខាងទៀតស្អាត, ដូច្នេះបើខាងទទួលគឺមែន មិនមានហើយ ខាងបដិសេធគឺមិនមែន នោះក៏មានមិនបាន, បើអត្តា ខ្លួនប្រាណ) មិនមានប្រាកដហើយ អនត្តា (មិនមែនខ្លួន) នោះ

ក៏មិនមានដូចគ្នា ។ ប្រការមួយទៀត បើព្រះនិព្វានមិនជាអ្វីៗមិនជាខ្លួនហើយ អរិយមគ្គ ៨ ប្រការនោះ មានទុកធ្វើអ្វី? ព្រោះអរិយមគ្គជាហេតុនៃវិពាកធម៌គឺនិព្វាន, កាលខំស្វាហាប់ធ្វើហេតុគឺអរិយមគ្គ ឲ្យចំរើនជាស់ក្លា រហូតកើតផលគឺព្រះនិព្វាននោះឡើងហើយ ក៏បដិសេធបន្ទៀតថាមិនមែនជាអនត្តា (មិនមែនខ្លួន) យកអ្វីកេះ? ដូចទឹកទឹងសាប៊ូជាគ្រឿងលាងបោកជម្រះញើសក្អែលកង្វក់កាយ បើសេចក្ដីបរិសុទ្ធិ៍ម៉ត់ចត់ ជាផលនៃការលាងជម្រះ មិនជាអ្វីហើយ ទឹកទឹងសាប៊ូរកប្រយោជន៍គ្មានគ្រឿងនោះគ្មាន ។

អស្មិមានៈ ថែប្រថា "សេចក្ដីប្រកាន់ថាយើងជា" គឺយើងជានោះជានេះ ដូចជាខន្ធ ៥ ឬការៈទីតែងតាំងឡើងជាកិលេសក្លាខ្លាំងតែទៅចូលចិត្តអស្មិមានៈនោះថា "សេចក្ដីប្រកាន់ថាយើងមាន" ទើបពោលប្រដៅគ្នាថាយើងមានមិនបាន ត្រូវដកយើងចេញ ទើបផុតចាកកិលេសនោះ នេះជាសេចក្ដីចូលចិត្តខុស ។

(មានត)

ការអ្នកភាគ

# ព្រះមហា ឱម-ឆាគ្រី

ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង រៀបរៀង

ឃុនសុវត្ថិផលទ៍ ឃួរ-អ៊ុន ពិនិត្យកែ

---

១ – បុគ្គលណានៅនាលោកនេះ / សំឡាប់សំឡេះបេះបំបាត់
ប្រហារជីវិតសត្វ / កាប់កាត់ពិឃាតប្រទូសរ៉ាយ ៗ
បុគ្គលនោះឯងលុះស្លាប់ទៅ / រមែងកើតនៅក្នុងអបាយ
បើកើតជាមនុស្សតែងអន្តរាយ / ជីវិតនឹងក្លាយអាយុខ្លី ៗ
២ – ជនណាវៀរបាណាតិបាត / មិនបានពិឃាតសត្វអ្វីៗ
ដោយចិត្តអាណិតគិតប្រណី / សត្វលើផែនដីផងនានា ៗ
ជននោះលុះផុតរលត់ខន្ធ / តែងបានទៅកាន់ស្ថានសួគ៌
បើកើតជាមនុស្សធម្មតា / លោកថាតែងមានអាយុវែង ៗ
៣ – ជនណាបៀតបៀនធ្វើបាបសត្វ / ដាល់តប់វាយវាត់ទាត់ធាក់ប៉ែង
ឲ្យឈឺឲ្យថប់ឲ្យស្រេង / ឲ្យក្រែងខ្លបខ្លាចអំណាចខ្លួន ៗ
ជននោះលុះស្លាប់វេលាណា / តែងរងទុក្ខាអបាយបួន
បើកើតជាមនុស្សតែងឈឺខ្លួន / រោគារុករួនច្រើនឈឺចាប់ ៗ
៤ – ជនណាមានចិត្តអាណិតសត្វ / មិនវាយមិនវាត់មិនចាក់កាប់
មិនបៀតបៀនសត្វឲ្យឈឺចាប់ / ជននោះលុះស្លាប់វេលាណា ៗ

តែងតែទៅយោនយកកំណើត  ឧប្បត្តិកើតជាទេវតា
បើកើតជាមនុស្សសាន្តសុខា  លោកថាមិនសូវមានរោគា ។
៥ – ជនណាច្រើនក្រោធច្រឡោតខឹង  ប្រកាន់ធម៌តឹងអាងមានោ
ក្រញេវក្រញូវចិត្តពាលា  ទុជ្ជនោនោះកើតក្នុងនរក ។
បើបែរកើតជាមនុស្សជម្ពា  រូបកាយមុខាច្រើនអាក្រក់
មុខមាត់ដូចមៀមចិត្តកក់ម៉ក់  សម្បុរអាក្រក់សាប់សោះក្រោះ ។
៦ – ជនណាមិនសូវខឹងឃោរឃៅ  មិនមានមួម៉ៅក្តៅក្នុងពោះ
ខឹងកើតខំកាត់ឲ្យសូន្យសោះ  ជននោះលុះដល់ស្លាប់ជីវិត ។
តែងទៅកើតនៅសួគ៌សុខសាន្ត  បើបានកើតជាមនុស្សពិត
ច្រើនមានរូបល្អសម្បុរល្អិត  ជាទីត្រូវចិត្តគាប់នេត្រា ។
៧ – ជនណាផ្តេសផ្តាសផ្តើមទឹកចិត្ត  តែងគិតឈ្នានិះរិះឫស្យា
ប្រណែនទឹងលាភ, យសសក្តា,  សរសើរ, សុខា របស់គេ ។
ជននោះលុះអស់ជីវិតទៅ  រមែងកើតនៅក្នុងនិរយេ
បើកើតជាមនុស្សៗ ប៉ោឡៃ  ពុំមានយសទេច្រើនថោកទាប ។
៨ – ជនណាមិនមានចិត្តឫស្យា  មិនឈ្នានិះការណ៍គិតគន់លាភ
សក្ការបូជាទាំងខ្ពស់ទាប  ជាលាភរបស់អ្នកដទៃ ។
ជននោះលុះស្លាប់ជីវិតទៅ  ទៀងតែកើតនៅសួគ៌ាល័យ
បើកើតជាមនុស្សក៏មនុស្សថ្លៃ  ច្រើនមានសិរីសក្តាធំ ។

៩ – ជនណា មានចិត្តកំណាញ់ស្វិត  មិនមានអាសូរយាចកស្រមណ៍
មិនដែលឲ្យទានដល់អ្នកសុំ  ដោយខ្លាចរលំរលាយទ្រព្យ ។
ជនៈនោះលុះជីវិតក្សិណក្ស័យ  នឹងទៅកើតឰទុគ្គតិជាប់
បើកើតជាមនុស្សតែងក្រទ្រព្យ  ពីកើតទាល់ងាប់ទុគ៌តក្ដាត់ ។
១០ – ជនណា មានចិត្តល្អទូលាយ  ចំណែកចំណាយចាយសម្បត្តិ
ឲ្យទានដល់ស្មូមអ្នកខ្វាត់ក្វាត់ បព្វជិតនៅវត្តឬព្រាហ្មណ៍ស្រមណ៍ ។
ជននោះលុះស្លាប់ជីវិតទៅ  រមែងកើតនៅសួគ៌ឧត្តម
បើកើតជាមនុស្សក៏ស័ក្តិសម  ស្តុកស្តម្ភសម្បូណ៌សម្បត្តិគ្រប់ ។
១១ – ជនណា មានៈកោងក្រអឺត  កិរិយាឫកឡឹកមិនគោរព
មិនក្រាបសំពះចាស់លើសលុប  ឬអ្នកគួរគប់មានសីលវត្ត ។
ជននោះលុះដល់ជីវិតស្លាប់  ប្រាជ្ញប្រាប់ថាទៅទុគ្គតិធ្ងន់
បើកើតជាមនុស្សតែងអាប់អន់  ត្រកូលទាបទន់អន់ពូជពង្ស ។
១២ – ជនណា សុភាពកបរម្យទម  គោរពបង្គំភិក្ខុសង្ឃ
កោតខ្លាចព្រឹទ្ធាវ័យយូរលង់  មិនមានទ្រនង់ប្រឡោះបស់ ។
ជននោះលុះដល់ស្លាប់ជីវិត  នឹងទៅសណ្ឋិតសួគ៌សោឡស
បើកើតជាមនុស្សក៏ស្រួចស្រស់  ត្រកូលខ្ពង់ខ្ពស់មានយសស័ក្តិ ។
១៣ – ជនណា មិនស្មាគមសេពគប់  នឹងប្រាជ្ញប្រសព្វពន្យល់ដាក់
ចូលចិត្តគប់ខ្លាពាលអប្បល័ក្ខណ៍ ជាអ្នកកាច់ចាក់អបាយមុខ ។

ជននោះលុះស្លាប់ជីវិតទៅ តែងតែកើតនៅទំពោសទុក្ខ
បើកើតជាមនុស្សអវិជ្ជាល្មក លង់ទៅម្ហូរមុខអ័ប្បប្រាជ្ញា ។

១៤ – ជនណាចូលចិត្តសិក្សាគម បណ្ឌិតឧត្តមមានបញ្ញា
ហើយចំរៀនសូត្រសួរសិក្សា ធម៌អាថ៌ខុសត្រូវបាបបុណ្យ ។
ជននោះលុះដល់ស្លាប់ជីវិត តែងទៅកើតពិតសួគ៌សុខសុន្ទរ
បើកើតជាមនុស្សមិនយ៉ាកចុន មានប្រាជ្ញជោះកុនចេះអាថ៌ធម៌ ។

## និគមវិបន:

អំពើបុណ្យបាបបើបានសាង តែងជាពស្តុតាំងខាងឲ្យផល
កម្មថ៌កម្មចាស់ផ្លាស់ប្តូរផ្តល់ កុំសង្ស័យឆ្ងល់នាំសួញសាញ ។
ព្រោះសត្វមានកម្មប្រចាំប្រាណ គេបដៀសមិនបានប្រានមិនគ្រាញ
នរណាធ្វើបាប បាបប្រែទាញ ឲ្យទុក្ខទោសលាញវិនាសលាក ។
នរណាសន្សំធ្វើបុណ្យ បុណ្យនោះជាទុនវិញដកប
សុខទុក្ខផ្លាស់ប្តូរតាមបុណ្យបាប សូមគិតស្ទង់ស្ទាបគង់ឃើញអើយ ។

## ល្បើកគ្រោះជាតិ

# កាព្យពាក្យ ៧ តាមលំដាប់អក្សរ

ឃុនបណ្ឌានុរក្ស ប៊ូ - ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ក — កបកើតមកជាកូនខ្មែរ

ខ — ខំគិតបែរប្រែគំនិត

គ — គួរសេពគប់លោកបណ្ឌិត

ឃ — ឃើញត្រូវពិតរួបសឹមថា ៗ

ង — ងើបមើលជាតិខ្មែរដូចគ្នា

ច — ចូរសមគ្គាជួយរដ្ឋា

ឆ — ឆបប្រកបដោយបញ្ញា

ជ — ជួយស្តីថាតឿនកូនចៅ ៗ

ឈ — កុំឈប់ស្វៀមមើលបំណាំ

ញ — ញឹកខានចាំពាក្យប្រដៅ

ដ — ដឹងឲ្យគ្រប់កុំល្ងង់ខ្លៅ

ឋ — ថែមបេះដ្រោប្រឹងទៅមុខ ៗ

ឌ — កុំដុកដាន់ដោលគ្នាឯង

ឍ — ដើបុកខែងចង់ស្រណុក

ណ - ណាត់ញាះញង់ឲ្យអុកឡុក
ត - តោងសំកុកគិតឲ្យជ្រៅ ៗ
ថ - ថប់ៈទៅមុខក្រែងវិនាស
ទ - កុំទីសទាសបោលលំនៅ
ធ - ធៀបដូចទូកឬសំពៅ
ន - នៅមិននឹងមួយកន្លែង ៗ
ប - បើបានធំកុំស្អប់តូច
ផ - ផាត់កាត់ខូចចេញឲ្យស្អែង
ព - ពិតជាប្រុសខំប្រឹងប្រែង
ភ - ភ័យខ្លាចក្រែងជាតិខំគេ ៗ
ម - មកពីខិតខំរៀនសូត្រ
យ - យោងឲ្យរបួតប្រឹងរិះរេ
រ - រកឧបាយកលគ្នាន់គេរ
ល - លើកជាតិគេជាគួយ៉ាង ៗ
វ - កុំវិលវល់ទៅតាមខ្យល់
ស - សូមកុំធ្វល់ទងសំណាង
ហ - ហាមចិត្តខ្លួនកុំឲ្យអាង
ឡ - កុំឲ្យផ្លូងឡាងទាស់ទែងគ្នា ៗ

អ – អង់ស្ទង់ជាតិចាស់បុរាណ

អា – អាងភូមិឋាននៃវិជ្ជា

ឥ – ឥតប្រយោជន៍កុំទឹកនា

ឦ – ឲ្យការនាំតែចំរើន ៗ

ឧ,ឩ – ឧស្សាហ៍តែងក្បួនប្រាប់

ឬ,ឫ – កាន់កាប់ការឲ្យច្រើន

ឭ,ឮ – ត្រូវខំធ្វើឲ្យកើន

ឯ,ឰ – ចំរើនប្រទេសជាតិ ៗ

ឱ – ឲ្យសុខាដល់គ្នីគ្នា

ឳ – ឱបកំរងកុំឲ្យឃ្លាត

អុំ,អំ – បូវខំកុំរវេ

អាំ,អះ – ទើបជាតិខ្មែរថ្កើងអើយ ! ៗ

## ឆ្ងាយភ្នែក ឆ្ងាយចិត្ត

យ. អ.

# ការបណ្តុះនិស្ស័យ

## ព្រះមហាឧត្តមវិជ្ជា ធលញ្ញាណោ ប៉ុង-ប៉ម

*អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង*

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

ឯឧបាយកែខៃដ៏សំខាន់នោះ គឺត្រូវខ្វល់ខ្វាយសំដែងពាក្យប្រៀនប្រដៅអប់រំគេឲ្យដឹងទោសនៃការវៀចវេរ និងគុណនៃសេចក្តីស្មោះត្រង់ និងរកពិធីផ្លាស់និស្ស័យវៀចវេរឲ្យត្រឡប់ទៅជានិស្ស័យទៀងត្រង់វិញ ។ បើគេឃើញទោសនិងគុណព្រមទាំងពិធីផ្លាស់និស្ស័យហើយ ក៏នឹងលះបង់និស្ស័យវៀចវេញ ហើយប្រព្រឹត្តតាមនិស្ស័យទៀងត្រង់វិញឯង ។ បើមនុស្សយើងគោរពសេចក្តីទៀងត្រង់ នាំគ្នាយកសេចក្តីទៀងត្រង់មកប្រើយ៉ាងតិចបំផុតក៏ឲ្យបានស្មើនឹងការវៀចវេរហើយ មនុស្សយើងគង់តែឃើញថា សមគួរនឹងភាពជាមនុស្សមែនៗ ។ លោកដែលនឹងកើតចលាចល ក៏ព្រោះតែសេចក្តីវៀចវេរ, ដែលនឹងស្ងប់រៀបរយ ក៏ព្រោះតែសេចក្តីស្មោះត្រង់ ហើយលោកនឹងឈានឆ្ពោះទៅកាន់សន្តិសុខក្នុងសភាពប្រក្រតីបាន ក៏ព្រោះតែសេចក្តីស្មោះត្រង់ដែរ ។

ការស្មោះត្រង់ជាហេតុឲ្យរុងរឿង មានការស្មោះត្រង់ ទៀងទាត់ ជាក់លាក់ពិតៗ នៃអធ្យាស្រ័យនិងសេចក្តីប្រព្រឹត្តិរបស់បុគ្គលជាលក្ខណៈ មានអាការផ្សាយរស្មីភ្លឺរុងរឿងប្រាសចាកមន្ទិលទោស និងការពិរុទ្ធគ្រប់យ៉ាង ជាដួងរស្មីដ៏ភ្លឺថ្លានៅជុំវិញ ធ្វើឲ្យទឹកមុខរបស់មនុស្សស្មោះត្រង់ស្អាតផូរផង់អស់សៅហ្មង ជារបស់បរិសុទ្ធក្នុងខ្លួនឯងនិងនៅជិតបង្កើយ ត្រូវការពេលណាបានពេលនោះ មិនចាំបាច់ត្រាច់ស្វែងរកទេ ។ មនុស្សស្មោះត្រង់ រមែងកាន់យកសច្ចធម៌ជាទីតាំង រក្សាសេចក្តីទៀងត្រង់ជាធំ មិនក្លែងសំដែងខ្លួនឲ្យល្អលើសសភាពពិត រក្សាខ្លួនឯងនិងការងារ របស់ខ្លួនគ្រប់យ៉ាងឲ្យដូចគ្នាតែ ១ ដោយរាប់អានសេចក្តីស្មោះត្រង់ថាជាគោលចារឹកក្នុងការអាជីវៈទូទៅ ។

ការវៀចវេរជាហេតុឲ្យងងឹត មានការវៀច ង លំអៀងក្លែងក្លាយប្រែប្រួលត្រឡប់ត្រឡិន នៃអធ្យាស្រ័យនិងដំណើរប្រព្រឹត្តិរបស់បុគ្គលជាលក្ខណៈ មានអាការងងឹតងងល់បិទបាំងខ្វបក្លែក បែកចិត្ត លាក់លាមលបលួច មានទឹកមុខដូចជាគួរសង្ស័យជាគ្រឿងចំណាំឲ្យស្គាល់ថាជាមនុស្សពាល ។ ការវៀចវេរជារបស់ផ្សំដែលលំបាកចាប់លំបាកផ្សំ តែបើរកមូលហេតុបានហើយ គង់នឹងប្រកបចូលគ្នាឲ្យបានរូបសណ្ឋានសមហេតុសមផលឡើង ។ ពាក្យកុហកតែមួយដែលពោលប្រៀបប្រាយប្រកប ឲ្យប្រហែលនឹងសេចក្តីពិតនោះ ត្រូវយកពាក្យកុហកដទៃជាច្រើនទៀតមកប្រើផ្សំ ដើម្បីជួយបំភ្លឺ ។

អ្នកសំដែងសេចក្ដីមិនពិត ដែលចាត់ថាជាមនុស្សរៀបរយនោះ ក៏ត្រូវតែប្រយ័ត្នខ្លួនខ្លាចភ្លាត់បំណាច់ជានិច្ច ដូចគ្នានឹងអ្នកដែលឈរលើដែកស្រួច ឬ មុខដាវដូច្នោះ សូម្បីនឹងថាខ្លួនអាចបិទបាំងសេចក្ដីមិនពិតដោយការកូតករបំណងនឹងបញ្ឆោតអ្នកដទៃឲ្យវង្វេងជឿក៏ដោយ ៗ ព្រោះការរៀបរយនោះ បើតាមពិតទៅ ត្រឡប់ជាបញ្ឆោតខ្លួនឯងវិញគឺសេចក្ដីជឹងនោះ ធ្វើខ្លួនឯងឲ្យសាត់អណ្ដែត បើករស្មីនៃកំហុសឲ្យប្រាកដដល់អ្នកដទៃ ៗ ព្រោះវត្ថុដែលមិនគួរធ្វើនោះ បើនរណាជំនះធ្វើហើយ អ្នកនោះក៏នឹងចូលក្នុងទំនងថា "ដំរីស្លាប់ យកចង្អេរបាំង" ដូចម្ដេចនឹងជិតបាន ឬដូចជាផ្សែងភ្លើង ដូចម្ដេចនឹងគ្របទុកបាន ត្រូវប្រាកដចេញមកឲ្យឃើញជាក់លាក់ជាធម្មតា ៗ

"អ្នកមានសេចក្ដីទៀងត្រង់គ្រប់ត្រា ជាមនុស្សល្អ គួរសរសើរពិត ៗ" នេះជាពាក្យប្រែចេញមកអំពីសុភាសិតថា: "សាធុ រូបោ ច បាសំសោ ទ្វារត្តយេន សព្វទា" នេះឯងជាសេចក្ដីស្មោះត្រង់ ដែលបំណងយកក្នុងទីនេះ មិនមែនសំដៅយកតែការប្រព្រឹត្តទៀងត្រង់តាមផ្លូវកាយ ១ ទេ គឺត្រូវប្រកបដោយសេចក្ដីស្មោះត្រង់គ្រប់ទ្វារទាំងអស់ឲ្យដូចគ្នាទាំងខាងក្រៅទាំងខាងក្នុង ៗ សេចក្ដីស្មោះត្រង់មានប្រភេទតាមលក្ខណៈ ដែលប្រាកដក្នុងរូបបុគ្គលនោះ ៦ ប្រការ គឺ: ស្មោះត្រង់ចំពោះខ្លួនឯង, ស្មោះត្រង់ចំពោះកាយ, ស្មោះ

ត្រង់ចំពោះការងារ, ស្មោះត្រង់ចំពោះនាទី, ស្មោះត្រង់ចំពោះបុគ្គលនិង ស្មោះត្រង់ចំពោះគណៈ ។

ស្មោះត្រង់ចំពោះខ្លួនឯង ការចង់ធ្វើល្អ ចង់បានសុខ ជាកំពូលបំណងរបស់មនុស្សគ្រប់គ្នា គ្មាននរណាសូម្បីតែម្នាក់ចង់បានអាក្រក់ឡើយ ។ តែបើចង់បានឲ្យដូចបំណង ត្រូវតែជាមនុស្សស្មោះត្រង់ចំពោះខ្លួនឯង ប្រព្រឹត្តល្អឲ្យត្រង់គ្នានឹងគោលបំណងរបស់ខ្លួនឯង គឺធ្វើល្អវៀរអាក្រក់ ដើម្បីឲ្យខ្លួនបានល្អបានសុខផុតអំពីទុក្ខ ធ្វើអំពើល្អដែលខ្លួនបំណងនោះឲ្យបានល្អទីបំផុត លះបង់អំពើអាក្រក់ឲ្យដាច់ស្រឡះ និងវៀរអំពើអាក្រក់ឲ្យឆ្ងាយក្រៃលែង, កុំសារ៉ាក្នុងកាលប្រព្រឹត្ត, សេចក្ដីល្អយ៉ាងណា ត្រូវប្រព្រឹត្តធ្វើយ៉ាងនោះឲ្យពិតៗ កុំកូតករ, នៅចំពោះមុខគេប្រព្រឹត្តយ៉ាងណា សូម្បីកំបាំងមុខគេ ក៏ត្រូវប្រព្រឹត្តយ៉ាងនោះ, កុំសង្ស័យក្នុងកាលដែលមិនបានទទួលផលនៃសេចក្ដីល្អដែលខ្លួនប្រព្រឹត្ត, កុំខ្លាចប្ដញាប់ញ័រក្នុងកាលអ្នកដទៃពោលបាក់រុក ឬ ឡកឡឺយឲ្យ, សូម្បីមានពួកព្រេនដឹកនាំទៅ ដើម្បីឲ្យខូចបង់សេចក្ដីល្អរបស់ខ្លួន ក៏កុំទោរទន់តាម គួរគោរពតែក្នុងសេចក្ដីល្អរបស់ខ្លួន និងរក្សាខ្លួនឲ្យគង់វង់នៅល្អជានិច្ច ។ បើធ្វើបានដូច្នេះ ឈ្មោះថាលោក អ្នកជាមនុស្សរឹងប៉ឹងខ្ជាប់ខ្ជួនក្នុងសេចក្ដីល្អ មានសេចក្ដីស្មោះត្រង់ចំពោះខ្លួនឯង អាចនឹងប្រព្រឹត្តសេចក្ដីល្អបានយូរអង្វែង ។

(មានត)

មនុស្សវៀចវេរចំពោះខ្លួនឯង សូម្បីចង់ល្អ ក៏មិនអាចប្រព្រឹត្ត សេចក្តីល្អឲ្យពេញលេញបាន ព្រោះថាចង់ល្អ តែចូលចិត្តធ្វើការងារ លឹបលៗ លេងៗ ញ៉ុចៗ តិចៗ មិនជាដុំកំភួន ខ្ជិលច្រអូសចំពោះការងារ ធ្ងន់ទឹងការងារធំៗ ដែលជាដុំកំភួន ខ្ជិលច្រអូសចំពោះការងារតូចតាច ដែលមានដំឡៃច្រើន ដោយឃើញថាជាការងារថោកទាបជាការងារ សម្រាប់ថ្នាក់កម្មករ ជាការងារដែលនាំឲ្យអាប់មុខ ៗ កាលចង់បានល្អ តែមិនបានផលល្អភ្លាមៗ ហើយ ក៏កើតខ្សោយកំឡាំងចិត្តលែងធ្វើការអ្វី ឲ្យជាធំដុំតទៅទៀត ប៉ុន្តែខាងកុហកបញ្ឆោតខ្លួនឯង មានការខ្ជិល ច្រអូសជាត្រីមុខ សំគាល់ការខ្ជិលច្រអូសថាប្រសើរ ចិត្តមិនស៊ូ ចូល ចិត្តតែអាងលេស អាងហេតុបន្តិចបន្តួច ថាព្រឹកពេក ថ្ងៃពេក ល្ងាច ពេកជាដើម ចាំស្អែកសឹមធ្វើ តែលុះដល់ព្រឹកឡើងក៏មិនធ្វើ ឬសូម្បី ធ្វើខ្លះ ក៏គ្រាន់តែជាអាការលឹបលញ៉ុចញ៉ើមប៉ុណ្ណោះ ជាមនុស្សត្រឡប់ ត្រឡិន ធ្វើមិនពិតប្រាកដតាមសេចក្តីល្អ ជាមនុស្សមានពុតត្បុតធ្វើ ល្អតែនៅចំពោះមុខគេ ជាមនុស្សសាថយ្យអួតអាង ធ្វើល្អដោយបំណង ទឹងបង្អួតគេ ជាមនុស្សធ្វើល្អយកមុខ គឺបើសេចក្តីល្អនោះ ជាការជួយ អនុគ្រោះមនុស្សដទៃ ទឹងជាកិច្ចដែលត្រូវធ្វើទាំងចំពោះមុខទាំងកំបាំងមុខ ក៏បែរជាធ្វើត្រឹមតែចំពោះមុខគេ ទាំងជាមនុស្សកុហកលោក គឺធ្វើល្អ បំណងឲ្យមនុស្សជាច្រើន ចច្បូនិយមកប់អានខ្លួនថាជាមនុស្សល្អ តែ

កាលគេទៅអស់ហើយ ក៏លែងធ្វើសេចក្ដីល្អនោះវិញ នេះជាអាការលាក់កំបួចរបស់មនុស្សវៀចចំពោះខ្លួនឯងទាំងអស់ ៗ

លោក-អ្នកប្ដូរស្មោះត្រង់ចំពោះខ្លួនឯង កុំកុហកបញ្ឆោតខ្លួនឯង កុំជាមនុស្សត្រឡប់ត្រឡិន កុំជាមនុស្សបោកប្រាស កុំជាមនុស្សមាយាសាថេយ្យ កុំជាមនុស្សធ្វើល្អយកមុខ កុំជាមនុស្សបន្លំលោក និងកុំជាមនុស្សទោរទន់តាមសំដីដែលគេដឹកនាំឲ្យខូចសេចក្ដីល្អឡើយ ប្ដូរអាស្រ័យតែផលរបស់សេចក្ដីល្អ សន្សំតែសេចក្ដីល្អ អភិរម្យតែក្នុងសេចក្ដីល្អនោះ និងប្ដូរប្រកបតែសេចក្ដីល្អឲ្យខ្ជាប់ខ្ជួន កុំអាស្រ័យផលនៃសេចក្ដីល្អហើយទំលាយខ្លួនឯង ដោយការវៀចវេរឡើយ បើមិនដូច្នោះទេ និងត្រូវគេតិះដៀលថា គ្រាន់តែជាស្រមោលរបស់មនុស្ស ៗ ព្រោះមនុស្សវៀច សូម្បីមានសាច់ស្បែកជារូបជារាង គេអាចឃើញប្រាកដដោយភ្នែកបាន ក៏រាប់ថាត្រឹមតែជាស្រមោលមនុស្សប៉ុណ្ណោះ ៗ

-ស្មោះត្រង់ចំពោះវាចា·— លក្ខណៈនៃការស្មោះត្រង់ចំពោះវាចានេះ គេអាចដឹងបានត្រង់ការរក្សាវាចាឲ្យនិយាយតែតាមរឿងពិត និងធ្វើឲ្យពិតតាមពាក្យនិយាយ គឺរក្សាសំដីឲ្យនិយាយតែតាមសភាពពិតក្នុងការដឹកនាំគ្នាដោយវាចា និងរក្សាឲ្យពិតតាមវាចាដែលនិយាយដឹកនាំគ្នានោះ ៗ វិស័យអ្នកស្មោះត្រង់ចំពោះវាចានោះ សូម្បីនៅក្នុងទីកណ្ដាលអាវុធប្រង់ប្រាង ក៏មិនចរចាយ៉ាងដទៃក្រៅពីវាចាសច្ចៈរបស់

ខ្លួនដែរ មានលក្ខណៈស្មោះត្រង់ចំពោះភារពិតៗ ឥតមានទរណាអាចទំលាយបាន ទើបគួរតាត់មនុស្សបែបនេះ ថាជាអ្នករឹងដំហរក្នុងភាររបស់ខ្លួនគ្រប់ពេលវេលា ។

មនុស្សស្មោះត្រង់ចំពោះភារ ជាអ្នកមានមារយាទរៀបរយគុនលំពោន ធ្វើអ្វីក៏ជារបៀប មានសច្ចធម៌ជាបុសកែវ នេះជាលក្ខណៈនៃមនុស្សដែលពេញជាមនុស្ស បើផ្ទុយពីនេះវិញ ក៏ជាលក្ខណៈនៃម្រឹគក្នុងព្រៃ ។ មើលចុះ មនុស្សវៀចស្វែងរកសេចក្ដីល្អដើម្បីខ្លួន ដោយការប្រចុបប្រចែងញុះញង់ជានិច្ច មិនជួយគិត មិនជួយពិចារណា ជួយតែប្រចុបប្រចែងប៉ុណ្ណោះ គឺចេះតែអឺអើទាំងក្នុងកាលដែលគេធ្វើខុសទាំងក្នុងកាលដែលគេធ្វើត្រូវ សរសើរគេតែក្នុងទីចំពោះមុខ លុះកំបាំងមុខក៏និន្ទា បូលចិត្តសរសើរមនុស្សដែលគួរតិះដៀល និងតិះដៀលមនុស្សដែលគួរសរសើរ ។ ឯមនុស្សស្មោះត្រង់វិញ តែងស្វែងរកសេចក្ដីល្អដើម្បីខ្លួនដោយភារស្អាត ប្រាសចាកទោសជាគ្រឿងសៅហ្មងរបស់ភារ និងដោយការផារង់សុចរិតជាគ្រឿងសបរិសុទ្ធរបស់កាយកម្ម ។

(មានត)

# រឿងសាមកុក

## ភាគទី ១២

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ព្រះចៅហៀនតេទ្រង់ត្រាស់ប្រើតាំងដៀវឲ្យទៅហៅចូវ ឲ្យចូលមកប្រារព្ធកិច្ចរាជការ, តាំងដៀវក៏ម្នីម្នាយាត្រាចេញទៅ លុះទៅជួបនឹងចូវៗ ក៏សំឡឹងមើលលក្ខណៈរូបរាង ឃើញថាតាំងដៀវវៃរាងទាំងឫកពាកិរិយាពណ៌សម្បុរក៏ជ្រះថ្លាស្អាងស្អាត ដួងនេត្រាក៏មូលធំ ចិញ្ចើមផុតកន្ទុយភ្នែក ចូវឃើញប្លែកក៏សួរថា ក្មួយទី ក្នុងនេះខ្សត់អត់ស្បៀងអាហារ អស់បណ្តាជនក៏មានតែសេចក្តីទុក្ខអត់ឃ្លានណាស់ ហេតុម្តេចអ្នកឯង ចេះតាក់តែងរក្សារូបកាយឲ្យមានសាច់ឈាមលោមព័ណល្អសម្បុរស្អាតបាតបាន ។ តាំងដៀវឆ្លើយថា ខ្ញុំបាទនឹងបានបំរុង

ថែរក្សាដោយប្រការម្តេចក៏គង់អង្គឹមាន ខ្ញុំបាទទទួលទានតែអាហារដរាប មកដល់អាយុ ៣០ ឆ្នាំហើយ ។ ចូចូស្តាប់ហើយក៏អស់សំណើចហើយ សួរថា អ្នកឯងជានាហ្មឺនដំណែងអ្វី? ។ តាំងដៀវឆ្លើយថា ខ្ញុំបាទ ជាពួកអ្នកស្រុកគេងគោ ជាទីប្រឹក្សាអ៊ូនសៀវ លុះត្រាដំណឹងថា ព្រះចៅហៀនគេយាងត្រឡប់មកប្រថាប់នៅក្នុងស្រុកឡុកអៀងវិញ ក៏ចូល មកថ្វាយខ្លួនជាខ្ញុំព្រះរាជការ សព្វថ្ងៃទ្រង់ព្រះមេត្តាប្រោសព្រះរាជទាន ជាទី "ដៀងយ៉ឡុង" ប្រែថា "ទីប្រឹក្សាផ្ទាល់ព្រះអង្គ" ។ ចូចូតបថា "យើងត្រូវក្តីឈ្មោះអ្នកឯងមកយូរហើយ តែមិនដែលឃើញខ្លួនសោះ វេលានេះយើងបានមកជួបប្រទះក៏ជាបុណ្យភ័ព្វល្អណាស់របស់យើង" ថាហើយក៏រៀបលៀងអាហារហើយឲ្យហៅស៊ុនហុកមកបរិភោគជាមួយ ដើម្បីនឹងបង្ហាញឲ្យស្គាល់រាប់អានគ្នា ។ ចូចូនឹងតាំងដៀវ, ស៊ុនហុកបរិភោគត្រូវគ្នា ។

មានបំរើសេះចូលមកជំរាបចូចូថា ឃើញទាហាន ១ កងលើកចេញមកអំពីក្រុងឡុកអៀងចេញទៅទិសបូព៌ា តែមិនច្បាស់ជានរណា នាយទ័ពនោះ ។ ចូចូក៏ចាត់បំរើសេះឲ្យតាមទៅស៊ើបចង់ដឹង តាំងដៀវក៏ប្តឹងជំរាបថា កុំឲ្យលោកប្រើទៅធ្វើអ្វី នាយកងដែលលើកទាហានទៅនោះ ២ នាក់ ១ ឈ្មោះអៀវប៉ាង ជាបក្សពួកលីឈុយ, ១ ឈ្មោះហាន់សៀមជានាយចោរ បានចូលមកថ្វាយខ្លួនជាខ្ញុំរាជការផ្ទាល់គាល់ព្រះចៅ

ហៀនតេ ស្តេចទើបយាងចេញពីក្រុងតៀវហាន់ ឥឡូវនេះឃើញលោកចូលមកធ្វើជាការក្នុងស្រុកក្រុងនេះ ឈ្មោះទាំង ២ ភ័យបារម្ភខ្លាចលោក បានជានាំស្នំគ្រប់ក្រុពួកលើកទៅជ្រកពួននៅស្រុកគោលៀង ។ ចូឆូសួរថា ដែលឈ្មោះទាំង ២ នាក់ខ្លាចយើងហើយរត់ទៅនោះពីព្រោះហេតុអ្វី? ។ តាំងជៀវឆ្លើយថា វាដឹងថាដំរិះប្រាជ្ញារបស់លោកលើសហួសប្រាជ្ញាគំនិតរបស់វា បានជាខ្លាច ។ ចូឆូតបថា ដែលឈ្មោះទាំង ២ លបរត់ចេញទៅនេះ មុខជាមានសេចក្តីគិតធ្វើការផ្សេងៗ ជាការប្រទូសរ៉ាយដល់យើងហើយ ។ តាំងជៀវឆ្លើយថា អាទាំង ២ នេះ ឧបមាដូចខ្លាគ្មានចង្កូម ឬក៏ដូចសត្វឥតស្លាបហើយ បើវានឹងទៅគិតគំនិតយ៉ាងណា សូមកុំឲ្យលោកមានសញ្ញាជាវិតក្កឡើយ ខ្ញុំបាទយល់ថា យូរទៅឯមុខគង់នឹងចាប់ខ្លួនវាបានដោយងាយ ។

ចូឆូស្តាប់ហើយក៏គិតថា តាំងជៀវនេះចរចាមុតមាំណាស់ ទើបប្រឹក្សានឹងតាំងជៀវថា -ស្រុកឡុកអៀងនេះ ក៏ត្រូវអន្តរាយដោយភ្លើងឆេះវិនាសច្រើនណាស់ យើងនឹងត្រូវគិតប្រការម្តេច ។ តាំងជៀវឆ្លើយថា លោកលើកទាហានចូលមកកំចាត់ល៉ិឈុយគុយគីគ្រានេះ បីដូចលោកមានដំរះនឹងជួយព្រះចៅហៀនតេ នៅប្រជាជនឲ្យបានសេចក្តីសុខក្សេមក្សាន្ត គំនិតរបស់លោក នឹងជួយឧបត្ថម្ភទំនុកបំរុងផែនដី ហើយគុណបំណាច់ក៏គង់នឹងមានដល់លោកជា យ៉ាងថ្លៃថ្លាប្រពៃណាស់

តែថាទីនេះបើលោកនឹងតុបតែងកកំពែងលើកសែនដីគគូជាស្នាមភ្លោះ ប៉ុ នឹងធ្វើបន្ទាយឲ្យទូលាយធំខ្ពស់ក៏ពុំបាន ព្រោះអ្នកស្រុកក្រខ្សត់អត់ស្បៀងអាហារ បណ្ដានាហ៊ឺនខ្ញុំរាជការក៏នៅតាំងខ្លួនមិនមួនមាំ បើមានសឹកសង្គ្រាមលើកមកញាំញីក៏គង់នឹងលំបាកដល់អាណាប្រជានុរាស្ត្រ នឹងខ្លួនលោកជាប្រាកដ ខ្ញុំបានយល់ឃើញថាស្រុកហ៊ូគោជាទីធំទូលាយសប្បាយដោយមនុស្សម្នាមហាជនច្រើនណាស់ ទាំងស្បៀងអាហារក៏មិនមានខ្វះខាតបរិបូណ៌ជាងខែត្រខ័ណ្ឌដទៃ ប្រសិនលោកនឹងយកជាទីសមរភូមិជ័យនៃដែនខែត្រនោះចំពោះជាស្រួលណាស់ ហាក់បីដូចជាលោកបេះក្លែងផ្កាសំនិមិត្តទីថ្វាយព្រះចៅហៀនតេ ដោយបុញ្ញាបុទ្ធិរបស់លោក សូម្បីព្រះហឫទ័យព្រះចៅហៀនតេ នឹងនាហ៊ឺនសព្វមុខមន្ត្រីទាំងក្នុងក្រុងនឹងខែត្រក្រៅ ក៏មានទូវពាក្យសរសើរតំរិះប្រាជ្ញាលោកទូទៅ ទាំងបណ្ដារាស្ត្រក៏មិនមានសេចក្ដីក្ដៅក្រហាយ ខ្ញុំបាទអធិប្បាយតាមសេចក្ដីយល់ដូច្នេះ ស្រេចហើយតែលោកត្រិះរិះមើលតាមអធ្យាស្រ័យដោយគួរចុះ ។

បូចូបានស្ដាប់ដូច្នោះក៏មានសេចក្ដីត្រេកអរពន់ប្រមាណ ក្រោកឡើងចាប់ដៃតាំងជៀវហើយនិយាយថា ដែលអ្នកពណ៌នាមកដូច្នេះត្រូវនឹងគំនិតយើងគិតណាស់ តែថាបើយើងនឹងអញ្ជើញព្រះចៅហៀនតេស្ដេចយាងទៅកាលណា ក្រែងអៀវហាងនឹងហាន់សៀមលើកគ្នាមកធ្វើ

អន្តរាយកណ្តាលផ្លូវទេដឹង ប្រការ ១ បណ្តានាហ៊ឺនសព្វមុខមន្ត្រីតូចធំក្នុងក្រុងនេះ ក៏មិនទាន់ដឹងនឹងយល់ព្រមដូចយើងដែរឬទេ? ។ តាំងវៀរឆ្លើយថា សព្វថ្ងៃនេះបណ្តានាហ៊ឺនមុខមន្ត្រីនឹងបណ្តារាស្ត្រទាំងស្រីប្រុសក្នុងទីក្រុង ក៏ក្រខ្សត់អត់ឃ្លានដាច់ស្បៀងអាហារច្រើនណាស់ សូមឲ្យលោកប្រកាសឲ្យដឹងគ្រប់គ្នាថា ឥឡូវនេះក្នុងស្រុកឡុកអៀងក្រខ្សត់អត់ឃ្លានដាច់ស្បៀងអាហារណាស់ លោកនឹងអញ្ជើញព្រះចៅ-ហៀនតេស្តេចទៅគង់ឯស្រុកហ៊ូតោនៅជិតគ្នានឹងស្រុកឡោអៀង ស្រុកនោះសម្បូណ៌សប្បាយដោយស្បៀងអាហារចំណីត្រីសាច់មិនមានខ្វះខាតសោះ បើអស់នាហ៊ឺននឹងបណ្តារាស្ត្របានដឹងគ្រប់ហើយ ក៏គង់នឹងមានសេចក្តីត្រេកអរសាទរតាមលោក មួយយ៉ាងទៀត អៀវហង់នឹងហាន់សៀង ដែលរត់ទៅនៅស្រុកតៃលៀងនោះ ក៏សុំឲ្យលោកមានសំបុត្រទៅបញ្ចុះបញ្ចូលល្បួងលោមយកចិត្ត គង់នឹងមិនគិតប្រទូសរ៉ាយនឹងលោកតទៅ ។

ចូជូបានស្តាប់ក៏មានសេចក្តីត្រេកអរណាស់ ហើយនិយាយថា ចាប់តាំងពីថ្ងៃនេះតទៅ បើយើងមានកិច្ចការអ្វី នឹងសូមអញ្ជើញអ្នកឲ្យមកជួយពិគ្រោះប្រឹក្សាផង ។ តាំងវៀរទទួលពាក្យចូជូហើយក៏លាចេញទៅ ។ ក្រោយពីពេលនោះមក ចូជូបានប្រឹក្សាការនឹងសេនាទាហានឯទៀត អំពីរឿងដែលត្រូវអញ្ជើញព្រះចៅហៀនតេទៅគង់ឯស្រុកហ៊ូតោ តែការរឿងនោះមិនបានយល់ព្រមគ្នាសោះ ។

ឯអន៍លិបទឹង់ឡៀងឆាយ ជាពូជព្រះរាជវង្សទឹងប្រហៅហៀនតេបាន ប្រែក្បាគ្នា អន៍លិបថាខ្ញុំបានឃើញផ្កាយថៃប៉េក គឺផ្កាយសនោះក៏ថា តែរដូវស្ប្រា តែថាដល់រដូវប្រាំងកាលណា ក៏ដើរចូនមកត្រឡប់ស៊ុអន់អាប់អស់ទៅ ខ្ញុំពិចារណាតាមក្បួនខាងទៅឃើញថា ព្រះហៅ-ហៀនតេ ទឹងចុះពសីសាបសូន្យគ្រានេះ ហើយទឹងមានអ្នកដទៃមកសោយរាជសម្បត្តិជាព្រះមហាក្សត្រវិញ ។ អន៍លិបក៏នាំយកសេចក្តីនោះលបចូលទៅ ក្រាបទូលព្រះហៅហៀនតេៗ ទ្រង់ព្រះសណ្តាប់ហើយមិនមានត្រាសថាប្រការម្តេច ។

ចូធូបានឮកិត្តិស័ព្ទដែលអន៍លិបទឹងឡៀងឆាយនិយាយគ្នានោះ លុះពេលយប់ក៏ប្រើមនុស្សជំនិតឲ្យទៅនិយាយនឹងអន៍លិបថា បើខ្លួនអ្នកមានចិត្តសុចរិតត្រង់នឹងផែនដីហើយ ទោះបានជង់ឃើញហេតុកើតទ្រស់ទេសប្រការម្តេច ក៏កុំអាលនិយាយឲ្យបែកខ្ចាយផ្សាយសេចក្តីជាមុន ព្រោះការនេះជ្រៅធំពន្លឹកណាស់ ។ មនុស្សបំរើក៏ទៅនិយាយនឹងអន៍-លិបតាមពាក្យចូធូបង្គាប់នោះគ្រប់ប្រការ ។ អន៍លិបក៏មិនបានថាប្រការម្តេច ចូធូក៏ឲ្យហៅស៊ុនហុកមកនិយាយទៀត តាមដំណើរដែលអន៍លិបនិយាយគ្នានោះ ។ ស៊ុនហុកឆ្លើយថា ព្រះហៅហៀនតេកំណើតជាធាតុភ្លើង ខ្លួនលោកជាធាតុដី បើលោកនឹងគិតធ្វើការអ្វីក៏ត្រូវប្រឹងគិតឲ្យជ្រៅទូលាយជាដាប់ ដូចរឿងដែលលោកគិតទៅនៅស្រុកហ៊ូតោនោះ

ត្រូវទៅជាប្រញាប់កុំបង្អង់ លោកក៏គង់នឹងសម្រេចដូចពាក្យអង់លិបថាជាប្រាកដណាស់ ។

ប៊ូប៊ូបានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរពន់ប្រមាណ លុះពេលព្រឹកក៏ចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេហើយទូលថា ស្រុកឡុកអៀងនេះ មានសេចក្តីអន្តរាយវិនាសសាបសូន្យតាំងពីគ្រាតាំងតុះមុងហើយ ឥឡូវនេះព្រះអង្គទ្រង់យាងមកគង់ប្រថាប់វិញ ថែមទាំងទុរ្ភិក្សអត់ឃ្លានផង មានតែសេចក្តីលំបាកគ្រប់គ្នា បើនឹងតាក់តែងជាពង់កំពែងឡើងវិញកាលណា ក៏មានតែសេចក្តីវេទនាដល់អាណាប្រជានុរាស្ត្រខ្លាំងណាស់ ឯស្រុកហ៊ូតោនោះ ប្រកបដោយសែនបន្ទាយទូលាយធំមាំមួន អាណាប្រជានុរាស្ត្រសឹងតែមានទ្រព្យសម្បត្តិជាធនធាន មានទាំងស្រវេស្រវុចំណាំត្រីសាច់បរិបូណ៌ព្រម ហើយជិតនឹងស្រុកឡៅអៀងផង ប្រសិនបើមានសឹកសង្គ្រាមវេលាណាក៏នឹងបានលើកជួយគ្នាដោយស្រួលរហ័ស ទូលព្រះបង្គំខ្ញុំបានស្គាល់ច្បាស់មកយូរហើយ សូមអញ្ជើញស្តេចយាងទៅគង់គ្រងស្រុកនោះចុះ នឹងបានសេចក្តីសុខសប្បាយក្នុងព្រះកាយពល ព្រមទាំងនាហ៊ឺនមុខមន្ត្រីនឹងអាណាប្រជានុរាស្ត្រទាំងពួង នឹងបានសេចក្តីសុខក្សេមក្សាន្ត ។

ព្រះចៅហៀនតេទ្រង់ព្រះសណ្តាប់ហើយទើបត្រាស់ថា បើអ្នកនឹងគិតការពាររក្សាខ្ញុំយើងដោយប្រការម្តេច នោះស្រេចនៅលើគំនិត

របស់អ្នកចុះ  យើងមិនយល់ទាស់ទេ ។  ឯនាហ្មឺនតូច-ធំដែលជួបជុំបង្គំគាល់នៅទីនោះ  លុះបានឮបុប្ផទូលដូច្នោះសឹងខ្លាចអំណាចបុប្ផពល់គ្នា  មិនមាននរណាទឹងឆ្លើយទាស់ថាដូចម្ដេចឡើយ ។

ក្នុងសម័យនោះ,  បុប្ផក៏បង្គំឲ្យមនុស្សម្នាមហាជនប្រុស-ស្រីរៀបជញ្ជូនរបស់ទ្រព្យផ្ទុករទេះគោក្របី  ហើយនឹងធំសេនាទាហានមានសេះដំរីត្រៀបត្រារៀបទាំងព្រះរាជរថារួបស្រេច  ក៏អញ្ជើញស្ដេចព្រះចៅ-ហៀនតេ  នឹងព្រះអគ្គមហេសី  ស្រីស្នំឡើងគង់ព្រះរាជរថ  ខ្ញុំរាជការនឹងសេនាទាហានក៏ហែហមអមចេញទៅ ។  បុប្ផជាមេទ័ពលើកនាំស្ដេចចេញចាកព្រះរាជវាំងក្រុងឡូងអៀង  ទៅចម្ងាយផ្លូវប្រមាណ ៥០ សិន (២ គី ម.)  ដល់ជើងភ្នំ ១ ក៏ជួបប្រវះអៀវហាង  ហាន់សៀម  លើកទាហានស្រែកហ៊ោមកស្កាត់ពីមុខ ។  បុប្ផឃើញដូច្នោះក៏បរសេះស្ទុះទៅមុខទាហាន,  ស៊ីឡុងស្រែកឲ្យបុប្ផថា  អ្នកនាំព្រះចៅហៀនតេស្ដេចទៅទីឯណា ? ។  បុប្ផមិនឆ្លើយតប  ប្រើខាំផ្លូសេនាឯកចេញទៅតយុទ្ធនឹងស៊ីឡុងបាន ១៥ ក្បួនមិនទាន់តាញ់ឈ្នះ  បុប្ផឲ្យរាយឃោះថយត្រឡប់ក្រោយវិញ,  ស៊ីឡុងក៏រាថយទៅចូលក្នុងបន្ទាយ ។  បុប្ផប្រឹក្សានឹងសេនាទាហានទាំងពួងថា  អៀវហាងនឹងហាន់សៀមនោះ  យើងត្រូវគិតចាប់សម្លាប់ចេញចុះ  តែស៊ីឡុងនោះមានកំលាំងខ្លាំងពូកែយើងចង់បានទុកធ្វើសេនាឯក  បើដូច្នេះ  ត្រូវគិតកលឧបាយលួងលោមយកឲ្យបាន ។

(មានត)

# រឿងអារក្សថ្លែងរឿងខ្មៃប្រាំ

## លោកសាង-សាវ៉ាត លេខានុការ ក្រសួងហិរញ្ញវត្ថុ

*ប្រែពីភាសាបារាំងមកជាខ្មែរ*

(តមក)

## រឿងទី ៥

*អារក្សនិយាយថាដូច្នេះ "ឱមហាក្សត្រិយ៍! មានទីក្រុងមួយ ហៅថាក្រុងឧជ្ជេន (Ujjain) ។ ព្រះមហាក្សត្រនៃទីក្រុងនេះព្រះនាមព្រះបាទមហាបាល (Mahabal) មានអគ្គរាជទូតមួយឈ្មោះហរិទាស (Haridas) ។ ឯអគ្គរាជទូតនេះ មានកូនស្រីមួយល្អស្អាត ឈ្មោះនាងមហាទេវី (Mahadévi) ។ កាលណាអគ្គរាជទូតនេះឃើញបុត្រីពេញក្រមុំអាយុល្មមរៀបការអាពាហ៍ពិពាហ៍, លោកគិតរកប្ដីមួយឲ្យនាង ។*

*ថ្ងៃមួយនោះ នាងកញ្ញានិយាយទៅកាន់ឪពុកថា: "ឱលោកឪពុក! សូមលោកឲ្យខ្ញុំទៅមនុស្សពេញលក្ខណៈដែលមានគម្រឹះគ្រប់ចំពូក" ។ ឯឪពុកក៏ឆ្លើយវិញថា: "អើអញរៀបវិវាហមង្គលការឲ្យឯងបានទៅអ្នកណាមួយដែលមានវិជ្ជាសាស្ត្រគ្រប់បរិបូណ៌ទាំងអស់" ។*

*កន្លងថ្ងៃមួយ ព្រះមហាក្សត្រទ្រង់មានព្រះរាជឱង្ការឲ្យហៅលោកហរិទាសទៅជិតព្រះអង្គហើយទ្រង់មានព្រះបន្ទូលថា: "ចូរលោកអញ្ជើញ*

ទៅកាន់ប្រទេសព្រះបាទហរិចន្ទ (Harichand) ដែលសោយរាជ្យនៅខាងត្បូងខ្ញុំ ។ រួចលោកទូលសួរអំពីជីវភាពនិងសេចក្ដីសុខទុក្ខរបស់ព្រះអង្គផង ហើយយកដំណឹងនោះមកប្រាប់ខ្ញុំវិញ" ។

លុះទទួលព្រះរាជឱង្ការនេះស្រេចកាលណា ហរិទាស ក៏ក្រាបថ្វាយបង្គំព្រះបាទមហាបាលចេញទៅ ។ កន្លងច្រើនថ្ងៃមកក៏បានទៅដល់ប្រាសាទស្ដេចហរិចន្ទ ហើយលោកបានថ្វាយព្រះរាជសារព្រះបាទមហាបាលហើយក៏អង្គុយនៅជិតព្រះអង្គនោះទៅ ។

ក្រោយបន្តិច គេនិទានថា ថ្ងៃមួយនោះ ស្ដេចមានព្រះបន្ទូលសួរលោកថា: "ម្នាលហរិទាស! តើរយៈពេលដែលផុត ចាប់មានឡើងហើយឬនៅ?" ។ ហរិទាសឱបដៃក្រាបទូលព្រះអង្គវិញថា: "សូមទ្រង់ជ្រាប ពេលទុក្ខចាប់ផ្ដើមកើតមានហើយ ពីព្រោះពាក្យកុហកចេះតែមានច្រើនឡើងៗ ក្នុងលោកិយនេះ ឯសេចក្ដីពិតចេះតែថយទៅៗ ។ ក្នុងមាត់នៃមហាជនគ្រប់ខាងអស់សុទ្ធតែមានពាក្យល្អ ប៉ុន្តែជនទាំងអស់នោះលាក់របស់អាក្រក់ទុកនៅក្នុងដួងចិត្ត ។ អំពើយុត្តិធម៌ក៏ត្រូវគេរំលាយលះបង់ចោល ដោយមានមនុស្សហានេយ្យចេះតែកើតច្រើនឡើង ។ ភពផែនដីចាប់ផ្ដើមឲ្យផលតិច ។ ស្ដេចគ្រប់ព្រះអង្គចាប់ផ្ដើមដំឡើងពន្ធ ។ ពួកព្រាហ្មណ៍ ទៅជាមានចិត្តកំណាញ់ ។ ស្រីៗ ពុំបានតាំងចិត្តនៅនឹងធឹង ។ បុត្រលែងស្ដាប់បង្គាប់បិតារបស់ខ្លួន បងលែងទុកចិត្តប្អូន ។

រវាងមិត្តក៏ពុំមានសេចក្ដីមេត្រីសោះ ។ ពួកគ្រូអាចារ្យលែងមានចិត្តស្លូតត្រង់ ឯពួកទាសាទាសីក៏បោះបង់ការងាររបស់ខ្លួន ។ វត្ថុដែលអាក្រក់ទាំងប៉ុន្មានក៏លេចឡើង" ។

លុះកាលណា លោកក្រាបទូលតបព្រះមហាក្សត្ររួចហើយ ស្ដេចទ្រង់ក្រោកឈរឡើង យាងចូលទៅក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ។ ឯហរិទាសក៏ត្រឡប់ទៅកាន់លំនៅនៃខ្លួនវិញ ។ លុះលោកអង្គុយហើយ មានកូនប្រុសរបស់ព្រាហ្មណ៍ម្នាក់ទៅជិតលោក ហើយជំរាបលោកថា: "ខ្ញុំមករកព្រះតេជព្រះគុណ ដើម្បីសួរព្រះតេជព្រះគុណបន្តិច" ។

ហរិទាសនិយាយថា: និយាយមកមើល តើអ្នកចង់បានអ្វី? ។

— សូមព្រះតេជគុណមេត្តាឲ្យកូនស្រីរបស់ព្រះតេជគុណមកខ្ញុំបាទប្ដី? ។

ហរិទាសតបថា: "យើងឲ្យកូនស្រី ទៅមនុស្សណាដែលមានវិជ្ជាគ្រប់សព្វទាំងអស់" ។

លុះបានឮដូច្នោះ បុរសឆ្លើយតបទៅលោកវិញថា ខ្លួនមានវិជ្ជាគ្រប់គ្រាន់ដោយបរិបូណ៌ ។

ហរិទាសនិយាយទៀតថា: "មិនអីទេ ចូរអ្នកបង្ហាញតម្រិះរបស់អ្នកឲ្យយើងមើល ដើម្បីឲ្យយើងស្ទង់ថ្នាក់តម្រិះរបស់អ្នក" ។

យុវៈព្រាហ្មណ៍ឆ្លើយថា: ខ្ញុំធ្វើរទេះមួយដែលមានកង់បួន ឯរទេះនេះ អាចនាំលោកទៅដំបន់ដែលលោកចង់អញ្ជើញទៅបានក្លាមដូចប្រាថ្នា ។

ហរិទាសឆ្លើយថា: "អើដល់ព្រលឹមឡើង យករទេះនោះមកឲ្យយើង" ។

ដល់ថ្ងៃស្អែក មុនព្រះអាទិត្យរះឡើង បុរសនាំរទេះនោះមកជូនលោកហរិទាស រួចអ្នកទាំងពីរក៏ឡើងទៅលើរទេះនោះ ហើយក៏បានបរទៅដល់ទីក្រុងអុជ្ជេន ។

ប៉ុន្តែមុននឹងទៅដល់ក្រុងនោះ មានកូនព្រាហ្មណ៍ម្នាក់ទៀតបានទៅរកកូនច្បងរបស់ហរិទាស បានសុំរៀបការជាមួយនឹងនាងប្អូន ហើយទទួលការយល់ព្រមដូចមុន គឺថា: បុរសឲ្យប្អូនរបស់ខ្លួនទៅអ្នកណាដែលមានវិជ្ជាគ្រប់ជំពូក ។ ឯបុរសដែលចូលស្ដីដណ្ដឹងនាងនោះ បានបញ្ជាក់ថាខ្លួនចេះដឹងទាំងអស់ ហើយបានទាំងធ្វើកិច្ចសន្យាថែមទៀតផង ។

មានកូនព្រាហ្មណ៍ទីបី បានជូនពាក្យសុំដូចមុនទៅម្ដាយរបស់នារីដែលបានឆ្លើយដូចមុនថា នាងនេះនឹងបានទៅអ្នកណាដែលមានវិជ្ជាគ្រប់ជំពូក ។ ឯកូនរបស់ព្រាហ្មណ៍បានបញ្ជាក់វិញថា ខ្លួនមានវិជ្ជានោះយ៉ាងជ្រៅជ្រះ ហើយចេះទាំងបាញ់ព្រួញតាមសូរផង ។ ស្ត្រីជាមាតាក៏សុខចិត្តឲ្យបុត្រីទៅព្រាហ្មណ៍នេះ ។

គិតទៅគូកំណាន់បីនាក់ ទៅជួបជុំគ្នា ។ ឯហរិទាសក៏គិតថា ស្ត្រីម្នាក់ គូកំណាន់ដល់ទៅបី ... តើអញឲ្យទៅអ្នកណា ?... តើអញមិនឲ្យអ្នកណា ? ។

លោកអគ្គរាជទូតកំពុងតែដញ្ជឹងគិតដូច្នោះ ស្រាប់តែមានយក្សមួយចូលមកក្នុងពេលរាត្រីស្ងាត់ ចាប់យកនាងកញ្ញាទៅ រួចនាំនាងទៅលើកំពូលភ្នំមួយឈ្មោះវិន្ធ្យាចល (Vindhyachal) ។ គេនិយាយថា អ្វីដែលជ្រុលហួសប្រមាណ គឺអាក្រក់ទាំងអស់ ។ នាងសិតា (Sita) នាងនេះជាកូនស្ដេចជនក (janakas) ហើយជាភរិយារបស់ព្រះរាម (Rama) ព្រះរាមទៅធុតង្គ ទុកព្រះលក្សណ៍ (Lachmana) ជាប្អូនឲ្យរក្សានាង ។ ព្រះលក្សណ៍បានព័ទ្ធសីមាជុំវិញខ្លួននាង ។ ក្នុងពេលដែលព្រះលក្សណ៍មិននៅ យក្សរាពណ៍ (Râvana) ក្លែងខ្លួនជាអ្នកសុំទាន ទៅស្រឡាញ់នាងសិតា ហើយនាំនាងតាមរទេះរបស់ខ្លួនទៅ ។ រាពណ៍ស្រឡាញ់នាង ។ ស្ដេចពាលី (Bali) ធ្វើព្រះរាជអំណោយជាច្រើន ស្ដេចធ្លាក់ព្រះអង្គទៅជាក្រ ។ រាពណ៍ចិត្តឡើងក្រអើត:គាត់ធ្វើគ្រួសាររបស់គាត់ឲ្យហិនហោច ។

នៅចុងក្រោយបង្អស់ព្រះអាទិត្យក៏រះឡើង... នៅក្នុងផ្ទះគ្មានអ្នកណាមួយឃើញនាង គេតាំងនាំគ្នាស្មានជាច្រើនបែប ។ ជនស្ត្រីទាំងប័ដល់ដឹងដំណឹងនេះ ក៏មកដល់យ៉ាងប្រញាប់ ។ មានម្នាក់នោះជាអ្នកប្រាជ្ញ ។ ហរិទាសសួរព្រាហ្មណ៍នោះថា: "នែបណ្ឌិត! ចូរអ្នកប្រាប់ខ្ញុំតើកូនខ្ញុំនេះទៅណា ?" ។ លុះគិតចំនួនមួយម៉ោងព្រាហ្មណ៍ទី ១ នោះឆ្លើយថា កូនស្រីរបស់លោកត្រូវយក្សរក្សា យកទៅលើភ្នំ

បាត់ទៅហើយ ។ ព្រាហ្មណ៍ទីពីរបញ្ជាក់ថា ទៅសម្លាប់យក្ខនោះរួចនាំយកនាងមកវិញ ។ ឯព្រាហ្មណ៍ទីបី ប្រកាសថានឹងជិះលើរថរបស់ខ្លួនដើម្បីទៅរកនាង ។ ថាហើយព្រាហ្មណ៍ទី ១-៣ ធ្វើតាមពាក្យរបស់ខ្លួន ។ តែព្រាហ្មណ៍ទីពីរចេញទៅ សម្លាប់យក្ខហើយយកនាងនោះមក ។

ក្នុងពេលនោះ ជនទាំងបី ចាប់ផ្តើមប្រឈ្លោះគ្នា ឯឪពុកក៏ខ្វល់ខ្វាយជាខ្លាំង លោកគិតថា: "ទាំងអស់គ្នា បានជួយស្រោចស្រង់ជីវិតនាង ។ តើអញឲ្យនាងទៅអ្នកណា ? ... តើអញមិនឲ្យទៅអ្នកណា ?" ។

ដល់និយាយរឿងនេះហើយ អាក្រែស្សួរថា: "បពិត្រព្រះបាទពិករ័ន ! បណ្តាជនទាំងបី នារីនេះត្រូវបានទៅអ្នកណា" ។

ព្រះអង្គមានព្រះរាជឱង្ការថា "នាងត្រូវបានទៅអ្នកដែលសម្លាប់យក្ខ" ។

អាក្រែស្សនិយាយថា: សេចក្តីព្យាយាមរបស់ជនទាំងអស់មានស្មើតែគ្នា ហេតុម្តេចក៏អ្នកនោះត្រូវបាននាង ?" ។

ព្រះរាជាមានព្រះរាជឱង្ការថា: "បុរសទី ១-៣ មុននោះគ្រាន់តែមានគុណសម្បត្តិប៉ុណ្ណោះទេ ពីព្រោះសុទ្ធតែធ្វើទៅតាមមធ្យោបាយរៀងខ្លួន ឯចំណែកខាងបុរសទីពីរវិញ បានតតាំងនឹងយក្ខ សម្លាប់យក្ខនោះទៅ ហើយយកនាងមកវិញ អាស្រ័យហេតុនេះហើយ បុរសនោះត្រូវបានជាប្តីនាង" ។

លុះត្រាស់ដូច្នោះ អាក្រែស្សត្រឡប់ទៅលើព្រឹក្សារបស់ខ្លួនវិញ ឯព្រះអង្គក៏យាងទៅតាម យកអាក្រែស្សនេះមកចងលើព្រះអង្សាហើយនាំទៅ ។ (មានត)

# រឿងស្នេហាជាតិ

## ៤ ឈុត

លោក គង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(តមក)

---

### ឈុតទី ១ ឆាកទី ៤

### មិត្តភាព-មិត្តាណា

---

**មិត្តភាព**

*អាវុធ មានមុខជ៏សថ្វា          សម្រាប់ប្រហារជន្មជីវិត*
*មនុស្សអាក្រក់ដែលមានចិត្ត     កាណាវិទ្ធិចិត្តខ្មៅហើយឈាមការ ៗ*
*ផ្ញើបងអាងតែបុណ្យស័ក្តិធំ          វាយដំប្រចាក់ដោយគោរគារ*
*សម្លាប់អាចេញ ! បោលទូវកៀវ     រកការកើតឈ្មោះខ្ញុំឡើងវិញ ៗ*

**មិត្តាណា**

*សម្លាប់កាណាវិទ្ធិបងប្អូនឯង       ម្តេចមិនគិតក្រែងទុក្ខទោម្នេញ*
*លោកនឹងផ្តន្ទានិរទេសចេញ         បំណោញប្អូខាតឯងគិតមើល ! ៗ*

**មិត្តភាព**

*អាប់ស័ក្តិអាប់យសកេរ្តិ៍ឈ្មោះខ្ញុំ     កិរិយាមិនសម អាបងព្រើល !*
*មើលឃើញតែទោសខ្ញុំងងើល     គេប៉ុនស្រមើលមើលមិនឃើញ ៗ*

## មិត្តាណា

បងសូមអង្វរ ចិត្តប្អូនទៅ បើចិត្តប្អូនគៅ ចង់សង្ខើញ
កាយជាក់បងចុះ! គ្មានកំញើញ សង្ខើញតាមចិត្តឲ្យបាត់ទីង ។

## មិត្តភាព

បងបេះតែទទួលទុក្ខទោស នរណាគេខុស បងមិនដឹង
គេទទួលសាច់ បងយកឆ្អឹង ប៉ុណ្ណឹងហើយនៅតែខ្វល់ខ្វាញ់ ។

## មិត្តាណា

បងចង់ឲ្យប្អូនប្រុងប្រយ័ត្ន មានធម៌សមគ្គាបេះស្រឡាញ់
កប់អានបងប្អូនឥតមានគ្នាញ់ ដូចខ្ញាញ់ដែកហើយនឹងឆ្មាំងដែក ។
ស្រះស្រួលស្រឡាញ់ព្រមរកទាក់ បដិសណ្ឋារៈល្អអនេក
ផុំគ្នាបីដូចចង្កើះដែក ដោយដ័រយ៉ាងឯកគីសាមគ្គី ។
នរណានឹងហ៊ានហូតដកចេញ ចង្កើះដែកវេញជាប់ជល់ទី
បេះធ្វើដូចម្ដេចក៏មិនលី — លាចេញចោលពីគ្នាបានឡើយ ។

## មិត្តភាព

យល់ច្បាស់ក្នុងចិត្តសព្វសំដី ខ្ញុំឥតជាអ្វីទេបងអើយ!
តែនឹកទៅខ្វាសវណ៌តាកហើយ ពុំស្បើយទើបខ្ញុំកើតក្លាហាន ។

## មិត្តាណា

ខ្មាសស្រី! សម្រាប់បងប្អូនឯង ធ្វើឲ្យបំបែងចិត្តសន្តាន
ធ្វើដូចមនុស្សល្ងង់ខ្លៅសារៈមានឲ្យ នៃប្អូនប្រុសប្រាណលែងខឹងទៅ! ៗ

## មិត្តភាព

បើខ្ញុំលះចោលសេចក្តីគុំ គំនុំទៅមុខគេថាខ្លៅ
ខ្ញុំនឹងអន់ថយគ្មានឈ្មោះហៅ វណ្ណៈគាភៈងាមផ្តៅលែងអាណិត ៗ
រឿតនាងស្រឡាញ់ក្តីក្លាហាន ល្ងង់ខ្លៅសាមៈឡខ្ញុំឥតគិត
បានជាផុងខ្លួនឆ្ងាយគំនិត សម្រាប់ការណ៍ទ្វិដូចប្រាថ្នា! ៗ (ស្ទុះចេញ)

## មិត្តាណា (ចាប់)

ឈប់ៗ! ប្អូនប្រុសធ្វើមជីវិត ឯងទៅដេកគិតឲ្យអស្ចារ្យ
ពីរឿងដែលប្អូនបង់ប្រហារ ការណ៍ទ្វិគ្រសារគិតឲ្យជ្រៅ! ៗ
ឥឡូវត្រូវបោះកាំបិតចោល ចាំស្តាប់បងពោលពាក្យប្រដៅ
ធ្វើអ្វីគិតមុនទើបបានត្រូវ នេះហើយជាផ្លូវគន្លងធម៌ ៗ
តែបងឃាត់ប្អូនសូមនាងស្តាប់ ប្រញាប់ធ្វើតាមទើបបវរ
សម្រាប់បងប្អូនគ្មានគិតធម៌ ភជការទាក់ទៅដាក់គុក ៗ

## មិត្តភាព

ព្រោយចិត្តទាំងបងទាំងលោកប៉ា សេចក្តីហានក្លានឹងបានទុក្ខ
សំដីផងបងខ្ញុំចាំទុក បងអើយខ្ញុំសុខចិត្តស្រេចហើយ ៗ

### មិត្ដាណា

សាធុ! សាធុ! លោកទេព្ដា　ជួយចាំសច្ចាប្អូនគ្រាណាត្រើយ
ក្រមញាតិបេះស្រឡាញ់កៀកកើយ　ពីនេះទៅហើយលែងកលិយុគ ។

### មិត្តភាព

លោកចុះដឹងហើយ ឬ រឿងនេះ?　ស្រេចតែបងបេះខ្ចប់រៀបទុក
សច្ចាយ៉ាងនេះចំពោះមុខ　បងអើយអ្នកផ្ទុកសព្ទសំដី ។
វណ្ណីតាកខ្ញុំដកចិត្តចេញហើយ　នុបងប្រុសអើយរកជាតិស្ត្រី
ណាល្អលើសនាង ខ្ញុំមេត្រី　ដែលខ្ញុំស្វាមីអាចពឹងបាន ។

### មិត្ដាណា

ផលនារីជាប្អូនវណ្ណីតាក　លោកប៉ាបានស្ដីប្រកាន់ប្រាណ
អ្នកសុខាព្រមថាទឹងឲ្យបាន　រូបនាងកល្យាណល្អគួរស្នេហ៍ ។

### មិត្តភាព

រូបល្អអាក្រក់ខ្ញុំមិនគិត　ឲ្យតែគំនិតកិរិយាគេ
បេះថែរក្សាបេះកាញ់គ្នេរ　មិននៅទំនេរខ្ញុំស្នេហា ។
ប្រពន្ធរូបល្អតែកងកាយ　មិនបេះដាំបាយឥតត្រូវការ
ព្រលឹមឡើងប្រើឲ្យទៅផ្សារ　មិនបាច់ទាសាដើរតាមក្រោយ ។
ញ៉ិកញ៉ក់ញ៉ាំញ៉ីមិនចូលចិត្ត　ឪពុកខុសចិត្តមិនឲ្យផ្ដោយ
មិនមែនឃើញបេះតែបណ្ដោយ　ឪពុកត្រូវហើយទើបខ្ញុំយក ។ (ចូល)

ឈុតទី ១ ឆាកទី ៤

# ម៉ារ៉ា - មិត្តាណា - ផលនារី - ភាណី

### ម៉ារ៉ា

ហត់កាយ មិនស្មើនឹងហត់ចិត្ត   មានមិត្ត មិនស្មើមានគ្រួសារ
ទុក្ខអ្វីមិនស្មើក្តីស្នេហា   កើតឡើងកាលណា តែងអន្ទោល ៗ
ស្តីបន្ទោសវាជារឿយ ៗ   វានៅធ្វើឈ្លើយ បំភ្លេចចោល
ទៅណាតាមជាប់ដូចស្រមោល   អន្ទោលតាមប្រាណពិបាកថា ! ៗ
មិត្តាណា ! កូនប៉ា ចូរមកអាយ   ជួយស្រាយបំណងគឺបញ្ហា
លើកឲ្យថ្កុំថ្កើងដល់គ្រួសារ   កូនអើយ ! ដែលប៉ាជាទីពឹង ៗ

### មិត្តាណា

បញ្ហាអ្វីខ្លះ? សូមអធិប្បាយ   ខ្ញុំនឹងកំចាយ ជូនដំណឹង

### ម៉ារ៉ា

ភានរិទ្ធិ - ធ្លួតព្រោះស្នេហាដឹង   ធ្វើគ្រួសារហ្នឹងឲ្យថយក្រោយ ៗ

### មិត្តាណា

ហេតុការណ៍ទាំងនេះ សូមប៉ាជ្រាប   មិត្តភាពភាណរិទ្ធិចិត្តគេផ្ដោយ
បែកការដឹងដល់ក្នុងពេលក្រោយ   ភាណរិទ្ធិក៏ផ្ដាយវាយកត្រា ៗ
ញាប់ញ័រខឹងណាស់ចង់សម្លាប់   ខ្ញុំចាប់មិត្តភាពហើយស្តីថា
ព្រោះចោលពីដៃកាំបិតថ្លា   ខ្ញុំក៏ស្តីថាប្រដៅបាន ៗ

### ម៉ារ៉ា

កូនបេះនិយាយឲ្យគេស្តាប់ ឲ្យគេត្រងត្រាប់តាមលំអាន
ចូរកូនធ្វើចិត្តឲ្យតាមប្រាណ ក្រែងដូចលំអានជាផ្លែល្វា ៗ
ធ្វើកាយធ្វើចិត្តឲ្យត្រឹមត្រូវ ដើរទៅតាមផ្លូវព្រះសម្មា -
សម្ពុទ្ធជាម្ចាស់ទ្រង់ទេសនា ប្រោសសត្វទេព្តាឲ្យផុតផង់ ៗ
ឯងធ្វើគ្រូដូចជាបន្ទាត់ សម្រាប់គូសព័ទ្ធពត់តម្រង់
ឲ្យដើរទៅតាមផ្លូវដែលត្រង់ គន្ទងយ៉ាងខ្ជង់សម្រាប់រដ្ឋ ៗ
ប៉ុន្មានសតវត្សរ៍ហួសទៅហើយ កូនអើយ! ខ្មែរយើងល្បីប្រាកដ
គឺជាតិកម្ពុជានគរវត្ត សរសើរគ្រប់មាត់ថាស៊ីវិឡៃ ៗ

### មិត្តាណា

ការណ៍ណាដែលហួសលែងគិតជា! កវីភាសាទំនើបថ្មី
លោកគិតជ្រើសរកបែបសំដី ភាសាប្រពៃមកប្រើប្រាស់ ៗ

### ម៉ារ៉ា

ភាសាសំដីឥតបើថា ប៉ុន្តែមាសប៉ាកុំភ្លេចចាស់
ខ្មែរជាន់ពីដើមពូកែណាស់ ធ្វើកេរ្តិ៍ទុកច្បាស់ណាកូនអើយ ៗ

### មិត្តាណា

វិញ្ញាណមានរូបជាដំឡៃ ដូចប៉ា បានស្លាប់ទៅហើយ
ឥឡូវគេលែងនៅកៀកកើយ ផ្លាស់អស់ទៅហើយជីវិតធំ ៗ (ចូល)

ឆិលនារី

ប៉ាៗ! ខ្ញុំសូមទៅរាំបាល់ ទឹងនាងសារ៉ាល់ពួកម៉ាកខ្ញុំ

ម៉ារ៉ា

ទេ! ទេ! ទេ! ទេ! កូនក្រមុំ នាងកុំស្លៀកខោបញ្ចេញភ្លៅ ៗ
នាំឲ្យគេឃើញកើតក្ដាញ់ចិត្ត ស្លៀកបិទឲ្យជិតទៅកូនឪ!
តែជិះកង់ផុត! តាមឥឡូវ អាស្រូវគេក្ដីឈ្មោះដល់អញហើយ ៗ

ឆិលនារី

ស្លៀកអាហ្នឹងហើយទើបបានសម បញ្ចេញមាឌមាំដាក់ប្រុសៗ
ជេរម្ដាយអាក្មាមតែមាត់ថ្មោះ

ភាណី

រង្គោះមួយដៃថ្គាមយំឡែ ៗ ខ្លួនអើយឥតម៉ែយំខ្មាសគេ!
ទំពាំបានជេររ៉ាហូរហៃ

ឆិលនារី

នៅស្ងៀមៗ ទៅកុំបេះតែ ខ្មោចខ្មែរស្អប់ណាស់បងចង្រៃ ៗ
ខ្ទើមណាស់សំដី! កុំទំនើង

ភាណី

តិច! មួយជើងផ្កាសាយពាំថៃ (ខ្លាំង) កុំអាងបានប៉ាងហៃហៃ
អ្នកថៃតិចស្លាប់ដោយអញទាត់!... ៗ

ម៉ារ៉ា

អាក្រពះទក់មាត់ឲ្យតិចទៅ    អាណិតកូនពៅ! អាកុំមាត់
អាឯងធំហើយ    អញសូមឃាត់

ភាណី

ផលនារីមានមាត់ឲ្យខូចចុះ ៗ ភាណីពេញកំឡោះ នៅឲ្យនឹង!

ម៉ារ៉ា

និយាយទៅវឹង អារំបល់ចោស    និយាយនឹងអញសំដីថោស!
មើលចុះអាកូន!...

ភាណី

ឫកក៏ថ្ងៃ! ៗ

ផលនារី

ថ្ងៃតែឫកមារយាទថោក!    ប្រយ័ត្នស្រីបោកអស់ពីដៃ
នាលិកាចិញ្ចៀនមានដំឡៃ    តែស្រីត្រូវការបងដោះឲ្យ ៗ

ភាណី

មិនមែនឫកថោក ដូចភាណវិទ្ធ    និយាយមិនគិតនោះទេវើយ!
លោកប៉ាកូនប៉ាជ្រាបស្រាប់ហើយ    រឿងអ្វីក៏ដោយសុទ្ធកូនឯង ៗ
បំណោះវិជ្ជាមានសត្រូវខ្លួន    ដូចកូនបក្សីដុះស្លាបវែង
តែស្លាបក្រាស់ហើយចង់ជំទែង    គិតលែងសម្បុកហើរចាកចេញ ៗ

## ម៉ារ៉ា

ធ្វើម្ដេចកម្មព្រេងរបស់អញ　ដូចជាឆ្នាំងខ្លាញ់យ៉ាងណាមិញ
ចំរាញ់យកខ្លាញ់ក៏បានពេញ　យកចេញព្យួរចោលលែងរាប់អាន ៗ
ប៉ុន្ដែឪពុកឥតបើខឹង　ទិដ្ឋិនៅរឹងមិនសាមាន្យ
កូនចៅទាំងអស់ចិត្តក្លាហាន　រាបានប្រាប់ឯងថាសម័យ ៗ

## ភាណី

សម័យឲ្យគ្រួសារកម្មក្រាស　ចោកប្រាសឲ្យយើងចុះអន់ថ្លៃ
សម័យនេះហើយសែនចង្រៃ!　កុំយកមកច្នៃនាំតែហត់! ៗ

## ម៉ារ៉ា

ផលនារី! កូនស្រីអាណិតឪ　ផ្លាស់ខោចេញទៅស្លៀកសំពត់
បិទបាំងរាងកាយកូនឲ្យគត់　សំពត់នេះហើយចារិកខ្មែរ ៗ
ឪក៏ដឹងដែរ ភាពសម័យ　កុំធ្វើហួសក្រៃ មិនល្អទេ
ស្លៀកពាក់ខោអាវបិទបាំងក្ដ៏! តែឯងហួសគេ! ឈ្លើយ! គេថា ៗ

## ភាណី

ដេក ដើរ ឬឈរ អង្គុយគិត　គំនិតគិតឃើញ ពិចារណា
នឹងពោល បន្ទី សព្វវាចា　ចេញមកកាលណា ថាឬល្អក់ ៗ
ប្រយ័ត្នក្រែងខកខានបានល្អ　គឺជាផលល្អ ឬអាក្រក់

កុំស្រវឹងនុយ គេបង្អក តែខកដល់កការទឹងផ្ទែក ៗ
ប្រាជ្ញា យ៉ាងឯក ! អន្ទងប្រាណ រំខានទុក្ខព្រួយស្រក់ទឹកភ្នែក
រួមឈាមតែមួយ បែកពីរផ្នែក បំណែកសម្បកបានមកយើង ៗ
គិតទៅសំដីដែលខ្ញុំថ្លែង សំដែងយ៉ាងនេះឥតទំនើង
គេស្រវ៉ាសាច់បុកបបើង ឯងកែមិនឡើង អន់ជពប !!! ៗ

ចប់ឈុត ទី ១

មានទ្រព្យលើកឲ្យគេខ្ចីទៅ
តម្រេះបេះនៅតែកងក្បួន
ប្រពន្ធនៅឆ្ងាយអំពីខ្លួន
ដល់ជួនត្រូវការរអាបិត្ត ៗ

# រឿងប៉ូលនិងវីរ៉ស៊ីនី

## លោក ផេង-ជ្រើវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែរៀបរៀង

---

នៅខាងកើតភ្នំ ដែលមាននៅខាងក្រោយកំពង់ឈ្មោះ ពរ-ល្វី នា-កោះរបស់បារាំង គេឃើញមានខ្ទមចាស់តូចៗ ពីរដែលគេបោះបង់ចោលក្នុងទីវាលមួយ ។ ខ្ទមទាំងពីរនេះ ស្ថិតនៅស្ទើរតែចំពាក់កណ្តាលទីជ្រលងមួយពាសពេញសុទ្ធតែថ្ម ដែលមានច្រកចេញចូលតែមួយ នៅទិសខាងជើង ។ ខាងឆ្វេង មានភ្នំមួយឈ្មោះឡឺមនដឹឡាដេគូវែក ។ នៅលើភ្នំនុះ គេសំរប់ឲ្យដំណឹងអំពីកប៉ាល់មកចតនៅកោះ ។ នៅជិតភ្នំនុះមានផ្សារមួយឈ្មោះ ពរ-ល្វី ខាងស្តាំមានផ្លូវមួយទៅពីផ្សារនុះដម្រង់ភូមិមួយឈ្មោះបំភ្លើមូស គេឃើញមានវិហារបារាំងមួយនៅនោះដែរ ឆ្ងាយបន្តិចទៅទៀត ឃើញមានសុទ្ធតែព្រៃហូតដល់ចុងកោះ ។ នៅមាត់សមុទ្រ មានញកមួយឈ្មោះតោម្បូ ខាងស្តាំញកនុះមានជ្រោយមួយឈ្មោះម៉ាឡឺរើ ពីជ្រោយនេះទៅក្នុងសមុទ្រ មានកូនកោះពីរ-បីគ្មានមនុស្សនៅ ផុះលេចឡើងពីទឹកកណ្តាលរលកបោកបែកផ្កាត្រែង ។

នៅត្រង់ច្រកដែលចូលទៅក្នុងកន្លែងនោះ គេឃើញមានវត្ថុផ្សេងៗជាច្រើន ឮសូររំពងខ្យល់បក់នៅព្រៃជិតខាង និងសូររលកទឹកសមុទ្រដែលឆ្ងាយពីគ្នាមិនដាច់ តែនៅជិតខ្ទមនោះគ្មានឮសូរសំឡេងអ្វីសោះ គេ

ឃើញមានតែថ្មខ្សាច់ដូចជាកំពែងទីក្រុងជាតិ   លតាជាតិដុះតាមក្រហែងថ្ម  តាំងពីក្រោមដល់កំពូលលើ   វល្លិក្លៀងឥន្ទធនូពណ៌ល្អៗ ចាំងនៅពីខាងលើ ហើយមានស្ពានមួយតូចព្រារព្រៃៗ នៅទីនោះ ។ ត្រង់ប្រកកុំស្អាតស្ងៀប   មានតែព្រះពាយបក់មករហៀកៗ និងទឹកហូរស្រិបៗ ហើយនិងពន្លឺថ្ងៃបន្តិចបន្តួច ។

ខ្ញុំបាទចូលចិត្តនៅកំសាន្តក្នុងទីនោះ   ព្រោះស្អាតស្រួលហើយអាចក្រឡេកមើលក៏បានឆ្ងាយ ។ មានមួយថ្ងៃ ខ្ញុំអង្គុយនៅខ្នងទំនុះ ហើយសំឡឹងមើលប្រជាប់ដែលពោលនៅទីនោះ   ស្រាប់តែឃើញមនុស្សម្នាក់ចាស់ដើរមករក្បែរខ្ញុំ ។ អ្នកនុះស្លៀកពាក់ខោខ្លី អាវកូនចិនតាមទំនៀមបុរាណ ។ គាត់ដើរជើងទទេ កាន់ឈើច្រត់មួយធ្វើពីឈើខ្មៅ សក់សរព្រោង   តែទឹកមុខនៅស្រស់ហើយបែបមិនចេះប្រកាន់ ។ ខ្ញុំគំនាប់គាត់ដោយសេចក្ដីគោរព   គាត់ត្រឡប់គំនាប់ខ្ញុំមកវិញ ។ លុះសំឡឹងមើលខ្ញុំបាទសព្វៗ មួយស្របក់គាត់ក៏ដើរចូលមកជិត   ហើយអង្គុយលើដីទួលមួយដែលខ្ញុំបាទអង្គុយហើយនោះ ។ ដោយសេចក្ដីទុកចិត្ត ខ្ញុំក៏សួរគាត់ថា "បពិត្រលោកតាតុក! អ្នកប្រាប់ខ្ញុំបានឬទេ តើខ្ទមទាំងពីរហ្នឹងជារបស់អ្នកណា" ។ គាត់ឆ្លើយថា "ឱកូន! ខ្ទមហ្នឹង ដីហ្នឹង ជារបស់គ្រួកុលពីរដែលអាស្រ័យនៅប្រហែល ២០ ឆ្នាំហើយ ។ រឿងគ្រួកុលទាំងពីរនេះគួរឲ្យអនិច្ចាណាស់ ។ តែនៅត្រង់សមុទ្រផ្លូវទៅស្រុកកុង្គ តើ

ទឹងមានជាតិអឺរ៉ុបណា ចូលចិត្តចង់ដឹងរឿងកំទេចកំទីនេះ? តើអ្នកណាទឹងចង់រស់នៅសប្បាយ តែក្រហើយគ្មាននរណាស្គាល់ឡើយ? មនុស្សទាំងអស់ចង់ដឹងតែរឿងបុគ្គលមានយសសក្តិ ឬរឿងស្តេចដែលមិនមានអ្វីជាប្រយោជន៍ដល់អាត្មា” ។ ខ្ញុំនិយាយឡើងថា: “បពិត្រលោកឪពុក! គ្រាន់តែឃើញទឹកមុខនឹងព្រុសំដី ខ្ញុំបាទអាចយល់ថា លោកឪពុកជាអ្នកយល់ការខុសត្រូវច្រើន ។ បើលោកឪពុកមានពេល សូមមេត្តាពាយពាច់រឿងរបស់ជនដែលនៅក្នុងទីនេះ ឲ្យខ្ញុំបាទស្តាប់បន្តិច សូមលោកឪពុកជឿថា មនុស្សយើងសូម្បីជាអ្នកមិនជឿមនុស្សពុំណាគង់ចូលចិត្តចង់ស្តាប់ការសុខទុក្ខដែលកើតពីធម្មតាលោកនឹងធម៌ដែរ” ។ ឪកាសនោះ តាចាស់ធ្វើដូចជានឹករកនូវកាលវេលាដែលកន្លងផុតទៅ យកដៃដាក់លើថ្ងាស ហើយថ្លែងថា:

ក្នុង គ.ស. ១៧២៦ មានប្រុសកំឡោះម្នាក់ នៅស្រុក នរម៉ង់ឌី ឈ្មោះឡាតួរ កាលណារកស៊ីការធ្វើមិនបានឯប្រទេសបារាំង ហើយពួកសាច់ញាតិមិនជួយទំនុកបំរុងផង ក៏ដាច់ចិត្តមកនៅរកស៊ីក្នុងកោះនេះ ។ ចៅនេះមានប្រពន្ធមួយ តែងស្រឡាញ់គ្នាទៅវិញទៅមកអស់ពីចិត្ត ។ នាងនេះជាស្ត្រី នៃត្រកូលស្តុកស្តម្ភមួយ នៅក្នុងស្រុកដូចគេឯងដែរ ឡាតួរលបយកនាងនេះ ដោយស្ងាត់កំបាំង តែឪពុកម្តាយនាងមិនព្រមរៀបការឲ្យ ព្រោះគេថាចៅនុះមិនមែនជាពូជនៃអ្នកអម្បូរខ្ពស់ ។ ចៅ

ខ្ញាត្សួរ ទុកប្រពន្ធឲ្យនៅ ពរ-លូ៊ី ក្នុងកោះ ហើយខ្លួនក៏ចុះកប៉ាល់ទៅ ប្រទេស ម៉ាដាកាស្កា ដើម្បីរកទិញពូជពីរបីនាក់ ដោយមានបំណងនឹងត្រឡប់មកវិញយ៉ាងឆាប់នឹងផ្ញើផ្ទះនៅ ។ គាត់ចេញទៅវេលាពាក់កណ្ដាលខែតុលាដែលជារដូវមិនល្អ លុះទៅដល់ស្រុកគេមិនបានប៉ុន្មានថ្ងៃ ក៏ស្លាប់ទៅនឹងគ្រុនពិសទៅ របស់ទាំងប៉ុន្មានដែលនាំមកពីស្រុកនាយក៏អាពត់អាពយបាត់អស់ ។ នាងប្រពន្ធដែលនៅរង់ចាំឯកោះ ទៅជាស្រីមេម៉ាយមានផ្ទៃពោះផង គ្មានទ្រព្យអ្វីសោះ ហើយមានតែស្រីពូជម្នាក់នៅគ្រាន់បំរើជាគ្នា ។ ឈប់គិតត្រូវការនឹងប្ដីស៊ីដាច់ស្រឡះ ក្រោយដែលប្ដីនាងស្លាប់ទៅ. នាងញុំាងចិត្តក្លាហានឲ្យមានឡើងក្នុងសន្ដាន នៅបណ្ដាសេចក្ដីទុក្ខលំបាកដែលមកប៉ះពាល់ ។ នាងទេះពីរនាក់នឹងនាងពូជ ស្រុះចិត្តគ្នានឹងទៅរកដាំដំណាំក្នុងដីតូចមួយ ដើម្បីយកផលមកចិញ្ចឹមជីវិត ។

នាងមេម៉ាយនឹងនាងពូជចេញចាក ពរ-លូ៊ី ដើរណាក់ខ្លួនពួនអាត្មានៅក្នុងកន្លែងមួយដាច់ពីគេ ជារហោស្ថានមានដីគ្រាន់តែដាំដំណាំបានក្បែរជើងភ្នំមួយ ។

(មានត)

# អំពី សម្លៀកបំពាក់ខ្មែរ

របស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

ក្រុមជំនុំទំនៀមទម្លាប់បានកើតឡើងចំនួន ១៨ ឆ្នាំហើយ ប៉ុន្តែនៅមានជនជាច្រើនណាស់ពុំទាន់ស្គាល់ក្រសួងនេះនៅឡើយ ។

ជនខ្លះដែលបានឮសូរឈ្មោះក្រសួងនេះ តែងលាន់មាត់ថា " ឃើ! ស្រុកខ្មែរយើង មានក្រសួងទំនៀមទម្លាប់ដែរ ចុះក្រសួងនេះធ្វើការអ្វីខ្លះទៅ មានប្រយោជន៍យ៉ាងណាទៅ? " ។ ពាក្យឆ្ងល់បែបនេះ បង្ហាញឲ្យយើងឃើញថា ក្រុមជំនុំទំនៀមទម្លាប់ជាកន្លែងកប់ ព្រោះគេគិតស្មានថាជាការឥតប្រយោជន៍ ។

ក្នុងខណៈនេះ យើងសូមជំរាបអស់លោកអ្នកដែលតែងតែសួររកប្រយោជន៍ក្រុមជំនុំទំនៀមទម្លាប់ថា ក្រុមជំនុំនេះបានដំណើរមិនត្រឹមតែធ្វើឲ្យប្រទេសជាតិស្គាល់របស់អ្វីទាំងប៉ុន្មាន ដែលជាប្រពៃណីខ្មែរប៉ុណ្ណោះទេ ថែមទាំងរក្សាទុកនូវប្រពៃណីនេះទៅអនាគតផង ។ កន្លងយូរទៅលុះប្រទេសខ្មែរយើងមានអារ្យធម៌កាន់តែចំរើនឡើង ច្រើនតែភ្លេចទំនៀមទម្លាប់បុរាណទាំងឡាយ រកឫសរកគល់ពុំឃើញ ។

ហេតុដូច្នេះហើយ បានជាក្រុមជំនុំខំស្រាវជ្រាវរកប្រពៃណីអស់ទាំងនេះមករក្សាទុក, តទៅមុខជនណាចង់ដឹងរឿងរ៉ាវនេះមុខជានឹងមករកឃើញនៅមន្ទីរក្រុមជំនុំនៃពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញស្រាប់ ។

ក្នុងរឿងនេះ យើងចង់បង្ហាញឲ្យឃើញថា រឿងកំប្លែងប៉ុន្មានស្ទើរតែពិរោះពីសា បើកាលណាមានគោលការកត្រឹមត្រូវល្អ ហើយទីងរៀបរាប់ឲ្យបានសព្វគ្រប់ផង ។

លុះអំណើះទៅអនាគត ជីវភាពនៃខ្មែរយើងបានចំរើនខ្លាំងឡើង, រឿងកំប្លែងនេះអាចជួយឲ្យខេមរជនជាន់ក្រោយ សំដែងនូវសារតារជាតិរបស់ខ្លួនបាន ។

ម្យ៉ាងទៀត នាំឲ្យជននានាប្រទេសឃើញច្បាស់ថា ជនជាតិខ្មែរមានអារ្យធម៌ប្រហែលគ្នានឹងប្រទេសណា យ៉ាងណាខ្លះ ហើយនឹងប្លែកពីគេ យ៉ាងណាខ្លះ ។

ក្រុមជំនុំសង្ឃឹមថា ការបង្កើតឲ្យមានក្រសួងទំនៀមទម្លាប់ខ្មែរឡើងនាំឲ្យអ្នកចេះចាំទំនៀមទម្លាប់ខ្មែរទាំងឡាយ សរសេរតែងរឿងផ្សេងៗផ្ញើទៅក្រុមជំនុំតាមដែលខ្លួនបានចេះចាំ ។

ក្នុងឆ្នាំ ១៩៤១ ដែលទើបនឹងផុតទៅនេះ ក្រុមជំនុំបានទទួលឯកសារចំនួនជាង ២០០ ប្លែកៗ គ្នា, បើប្រសិនជាយកការទាំងអស់នេះមកអធិប្បាយក្នុងពេលនេះតែម្ដង ឃើញថាច្រើនពេកណាស់, ដូច្នេះយើងសូមរើសយកតែរឿងមួយមកអធិប្បាយជូនសិន ក្នុងខណៈនេះ

"អំពីសម្លៀកបំពាក់ខ្មែរ, ដោយមានបណ្ដាជនជាតិជាច្រើនចង់ដឹងដោយច្បាស់លាស់" ។

រឿងនេះ ការសែតកម្ពុជាបាននាំមកពណ៌នាម្ដងរួចហើយ ។

កាលសម័យមុនណា ខ្មែរអ្នកចេះធ្វើម្ហូបក្ដី • ចេះសិល្បអាគមក្ដី ចេះចាំទំនៀមផ្សេង ៗ ក្ដី ចេះស្ទាត់ខាងការត្បាញរវៃក្ដី ចេះសង់ផ្ទះ ចេះធ្វើរទេះគោ ឬធ្វើរបស់ឯទៀតៗ ក្ដី បង្រៀនតែត្រឹមកូនចៅខ្លួនប៉ុណ្ណោះ បើកូនចៅនោះយកចិត្តទុកដាក់ក៏ចេះចាំ ធ្វើដំណាងឪពុកម្ដាយទៅ, បើកូនមិនរវល់ទេ អំណើះពីឪពុកម្ដាយទៅ, គ្មានអ្នកណាដទៃទឹងអាចចេះផង ម៉្លោះហើយបានជាខ្មែរច្រើនតែល្ងង់ ដោយមិនបានគិតកត់ត្រាទុកជាក្បួនថែមទាំងបង្ហាក់បំណេះផង, ប៉ុន្ដែជាយូរឆ្នាំក្រែលមកហើយ ខ្មែរបានលះចោលគំនិតនេះខ្លះ ហើយអ្នកចេះដឹងគេចូលចិត្តចែកបំណេះទៅអ្នកឯទៀតឲ្យបានច្រើនគ្នា, ខ្លះទៀតក៏ទំកត់ត្រាទុកដើម្បីកុំឲ្យកប់ទៅជាមួយនឹងមរណភាពបាន ។

យើងតែងដឹងថា សម្លៀកបំពាក់ជាគ្រឿងសំគាល់ជាតិ បុគ្គលនិមួយ ៗ តែងមានចិត្តរីករាយចំពោះការស្លៀកពាក់ នូវសម្លៀកបំពាក់របស់ជាតិខ្លួន ជាជាងរឹបរៀបជាតិដទៃមកស្លៀកពាក់ជាដរាប ។ បើដូច្នេះ គួរតែយើងខំតុបតែងសម្លៀកបំពាក់យើងឲ្យបានផលប្រសើរល្អ ហើយដើម្បីមិនឲ្យសាបសូន្យប្រពៃណីខ្មែរសុទ្ធ ៗ ផង ។

អស់លោក អ្នកទាំងឡាយជ្រាបស្រាប់ហើយ ថាបណ្ដាពស្ត្រីខ្មែរសព្វថ្ងៃកំពុងតែរែករកផ្ទរចេញពីព្រៃស្បាកគីសេចក្ដីអាប់ឱនទៅរកសេចក្ដី

ចំរើន, តាំងសម្លៀកបំពាក់សោត ក៏ចេះតែផ្លាស់ប្តូររូបរាងទៅតាមកាលសម័យដែរ ។ ការដែលយើងនាំមកពណ៌នាជូនមានតទៅខាងមុខ មិនមែនយើងចង់ឲ្យអស់លោក អ្នកអាន អ្នកស្តាប់វិលត្រឡប់ថយក្រោយទេ គឺគ្រាន់តែឲ្យស្គាល់ឲ្យជ្រាបឲ្យដឹងសាវតាររបស់ខ្លួនយ៉ាងណាខ្លះ; តាំងនានាជាតិក៏គេនិយមរុករកគោលចារិក ដើមកំណើតទំនៀមទម្លាប់របស់គេឲ្យស្គាល់តាមពិតយ៉ាងនេះដែរ ។

តាមសេចក្តីកត់ហេតុរបស់អ្នកដំណើរជាតិចិនឈ្មោះ ជាវ-តា-គួន នឹងសេចក្តីឲ្យការរបស់សមាជិកប្រចាំខេត្តខ្លះ មានទំនងស្របគ្នាជាច្រើន ។

ក្នុងចំណោមនេះ អ្នកអង្គម្ចាស់ នរោត្តម-សុខានារី បានឲ្យការប្លែក ៗ ហេតុនេះយើងសូមស្រង់សេចក្តីនោះយកមកពណ៌នាជូនអស់លោកអ្នកអានស្តាប់ដូចមានតទៅនេះ ៖

## អំពីសម្លៀកបំពាក់ខ្មែរសម័យបុរាណ

(តាមដែលអ្នកអង្គម្ចាស់ នរោត្តម—សុខានារី ឲ្យការមក)

យើងសព្វថ្ងៃមិនអាចដឹងបានដោយសព្វគ្រប់ អំពីសំលៀកបំពាក់របស់បុព្វបុរសយើងទេ ដោយទំនៀមនេះ កន្លងជាយូរអង្វែងណាស់ទៅហើយផង ដោយយើងពុំមានឯកសារ ឬសៀវភៅឯណាកត់ត្រាទុកថាក្នុងសម័យនេះគេស្លៀកពាក់បែបនេះ, សម័យនោះគេស្លៀកពាក់បែប

នោះផង, តែដោយការសង្កេតមើលតាមរូបចម្លាក់ថ្ម ដែលមានសេសសល់អំពីប្រាសាទបុរាណបាក់បែកមក យើងក៏អាចយល់បានថា ក្នុងសម័យនោះបុព្វបុរសរបស់យើងស្លៀកសំពត់ចងក្បិន អាវកមូល ដៃធ្លាក់មកត្រឹមកំភួនដៃ ឬអាវកមូលតូចដៃវែងស្តួចឧបជាប់នឹងសាច់ ធ្លាក់ចុះមកត្រឹមចង្កេះ, ចួនកាលឃើញស្លៀកតែសំពត់ឥតអាវក៏មាន នេះចំណែកបុរស, ចំណែកស្ត្រីវិញឃើញស្លៀកសំពត់សំឡុយពានាស្បៃ ឬស្លៀកសំឡុយខ្លួនទទេមួយកំណាត់ក៏មាន ។

ចំណែកឯល្ខោនព្រះរាជទ្រព្យ របស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលរក្សារបៀបស្លៀកពាក់របស់ខ្មែរអំពីបុរាណ ឥតមានប្រែប្រួលនោះ យើងឃើញថា បុរសស្លៀកខោពីក្នុង ជើងតូចធ្លាក់ដល់ត្រឹមកំភួនជើង ហើយមានស្លៀកសំពត់ចងក្បិនពីលើខោថែមទៀត ព្រមទាំងមានចងផ្ចាំងក្រណាត់តូចវែងនៅពីមុខ នឹងនៅសង្ខាងចង្កេះផង នេះចំណែកបុរស, ឯចំណែកស្ត្រីឃើញស្លៀកសំពត់សំឡុយ ពាក់ស្បៃ ឬពានាផ្ទួយប៉ាក់ឌិនមាសព្រាក់ ៗ យើងក៏បានឃើញខ្លះដែរ កាលពីដើមប្រុសខ្មែរដែលប្រកាន់ទំនៀមបុរាណ ស្លៀកសំពត់ចងក្បិនជាមួយនឹងអាវកុតកត្រង់ ឬអាវឡេវកាឌុំ ដែលហៅថាអាវចិន ឬជាមួយនឹងអាវកមូលដៃខ្លីធ្លាក់ស្មើកែងដៃ ឬជាមួយនឹងអាវកសន្ទុះ ដៃធ្លាក់ត្រឹមកដៃ, ចួនកាលក៏ស្លៀកខោដែរ ដែលយើងហៅថាខោចិន ៗ ឯស្ត្រីខ្មែរវិញ ឃើញស្លៀកសំពត់

សំឡូយ សំពត់ចងក្បិន ពាក់អាវមានស្លាបតែខាងឆ្វេង ហើយពានាក្រមាវែង ដែលហៅតាមភាសាសៀមថាផាហ៊ុំ លើស្មាទាំងសងខាងសំយុងជាយទៅខាងមុខ ឬពាក់អាវបំពង់វែង កម្ពុលដៃតូច ធ្លាក់ដល់កដៃ ខ្លួនតូចចង្អៀតខ្លួំ ធ្លាក់ដល់ត្រឹមកំភួនជើង បង់កក្រមា, អាវម៉ាឡាយូ បង់កក្រមា, អាវសន្ទុះ បង់កក្រមា, នឹងអាវហាតាទិប ក្រវាត់ក្រមាឈៀងមួយចំហៀងខ្លួន ។

សំពត់ចងក្បិន កាលអំពីសម័យព្រេងនាយ មានតែបុរសទេ ដែលស្លៀកសំពត់ចងក្បិន ស្ត្រីមិនឃើញស្លៀកទេ ។ ឯសំពត់ចងក្បិន ដែលគេស្លៀកសម័យបុរាណក៏មិនដូចយើងសម័យបច្ចុប្បន្នទេ, បើតាមរូបចម្លាក់នៅជញ្ជាំងប្រាសាទបុរាណ គេឃើញស្លៀកខ្លីៗ នៅពាក់កណ្ដាលភ្លៅ សូម្បីពួកល្ខោនព្រះរាជទ្រព្យ ដែលជាសិល្បៈរក្សាទុកនូវទំនៀមសម្លៀកបំពាក់បុរាណមួយបែប ក៏ឃើញស្លៀកសំពត់ចងក្បិនខ្លីៗ នៅលើក្បាលជង្គង់ដែរ ។ ឯទំហំសំពត់ សម័យបុរាណប្រហែលប៉ុនគ្នានឹងទំហំសំពត់សម័យបច្ចុប្បន្នដែរមើលទៅ គឺទទឹង ១ ម៉ែត្រ បណ្ដោយ ៣ ម៉ែត្រ ២០ ។ របៀបស្លៀកនោះឃើញថាខុសគ្នាច្រើន អំពីបុរាណគេកន្កាញ់ជីបជាយសំពត់ទាំងសងខាងឲ្យនៅតែប្រវែងមួយជុំចង្កេះ រួចហើយគេស្លៀកដាក់ជាយសំពត់នោះត្រួតលើគ្នា ចងជាថ្នក់ហើយគេក្រវាត់ខ្សែក្រវាត់ដើម្បីមិនឲ្យរបូត ។ ឯជាយសំពត់ដែល

ដីបទាំងសងខាងគេដេរភ្ជាប់ដាក់ត្រួតលើគ្នា ហើយគេយកចុងជាយខាងក្រោមសើកតាមប្រឡោះជើងទាំងសងខាង យកមកចុកនៅចង្កេះខាងក្រោយ, ចំណែកសំពត់ចងក្បិនដែលយើងស្លៀកក្នុងបច្ចុប្បន្ននេះក៏មានទំហំប្រហែលគ្នាដែរ តែរបៀបស្លៀកខុសគ្នា គឺគេយកសំពត់មកស្លៀកទុកបោលជាយទាំងសងខាង នៅវែងអន្ទាយអូសដី ហើយឲ្យមានប្រវែងស្មើមុខក្រោយ ទោះខុសគ្នាក៏ខុសបន្តិចបន្តួចចំនួនត្រឹមមួយទះប៉ុណ្ណោះ រួចគេផ្គួបជាយទាំងសងខាងរួមគ្នា ហើយគេមួរ រួចហើយគេសើកតាមប្រឡោះជើងទាំងសងខាង យកចុងទៅចុកនៅចង្កេះខាងក្រោយ, ឯសំរុងសំពត់ដែលស្លៀកហើយគេឲ្យធ្លាក់ចុះនៅត្រឹមស្មងជើង ។

(មានត)

> ទំនៀមទម្លាប់ ជាព្រំដែន របស់ជាតិនិមួយៗ, អ្នកសិក្សាវិជ្ជាខាងទំនៀមទម្លាប់ របស់ជាតិ ឈ្មោះថា "អ្នកស្នេហាជាតិ" ។

# ពិធីបុណ្យកឋិន

## នៅវិទ្យាល័យស៊ីសុវត្ថិ ភ្នំពេញ

## របស់ក្រុមសាស្ត្រាចារ្យនិងក្រុមសិស្ស

---

ពល់តែឆ្នាំកន្លងថ្ងៃរាណខាងក្រោយចេញវស្សា ១ ខែ នៅវិទ្យាល័យ-ស៊ីសុវត្ថិ សឹងតែវិចិត្រ របនាដោយស្លឹកឈើ ផ្កាឈើ, ទង់ជាតិ, និងភ្លើងអគ្គិសនីរលេចពណ៌ក្រហមសខៀវ ភ្លឺព្រោងព្រាត ៗ ក្នុងវេលាយប់នោះមានព្រះសង្ឃចំរើនព្រះបរិត្ត រួចមានព្រះធម្មកថិកសំដែងព្រះធម៌ទេសនា ៗ បន្ទាប់មក ពួកសិស្សវិទ្យាល័យស៊ីសុវត្ថិ ចាប់ផ្ដើមលេងល្ខោនជារឿងបំភ្លឺជនរួមជាតិ ឲ្យស្គាល់គុណនិងទោស ប្រយោជន៍និងឥតប្រយោជន៍ និង លេងភ្លេងត្រូវតន្ត្រីពីរោះគួរជាទីចាប់ចិត្ត ៗ ព្រឹកឡើងសាស្ត្រាចារ្យនិងសិស្សទាំងឡាយ សឹងតែតែងខ្លួនស្លៀកពាក់ស្អាតបាត តាមទំនៀមជាតិខ្មែរដើររៀងគ្នាជាជួរ ដៃកាន់ត្រៃចីវរគ្រឿងបរិក្ខារនិងទេយ្យទានផ្សេង ៗ ដង្ហែចេញពីសាលាវិទ្យាល័យទៅតាមផ្លូវនានាក្នុងក្រុង រួចចូលទៅក្នុងអារាមនៅក្នុង ឬ ក្រៅក្រុង វេរប្រគេនទូវត្រៃចីវរចំពោះព្រះសង្ឃ រួចហើយក៏វិលត្រឡប់មកវិញ ៗ

ពិធីបុណ្យនោះហៅថា បុណ្យកឋិនរបស់ក្រុមសាស្ត្រាចារ្យ និងក្រុមសិស្សនៅសាលាវិទ្យាល័យស៊ីសុវត្ថិ ដែលមានសទ្ធាជ្រះថ្លាក្នុង

ព្រះពុទ្ធសាសនា បានព្រមព្រៀងគ្នាបរិច្ចាគធនធានរៀងខ្លួន បង្កើតធ្វើឡើងរាល់ឆ្នាំជាប់ជាទំនៀមរហូតមកដល់ឆ្នាំនេះ ។

កិច្ចដែលនឹងដង្ហែអង្គកឋិនទាននេះ ទៅថ្វាយព្រះសង្ឃគង់នៅវត្តណាទិមួយ មិនថាវត្តគណៈធម្មយុត្តិ ឬមហានិកាយទេ ស្រេចហើយតែស្លាកដែលចាប់បានឈ្មោះវត្តនោះ ។

នៅឆ្នាំ ១៩៥១ នេះ ក្រុមសិស្សបានចាប់ស្លាកត្រូវលើឈ្មោះវត្តមង្គលវ័ន (ស្វាយដង្គំ) សង្កាត់លេខ ៣ ក្រុងភ្នំពេញ ក៏នាំគ្នាហែកឋិនទៅប្រគេនព្រះសង្ឃគង់នៅវត្តទោះ ។

បុព្វហេតុដែលក្រុមសាស្ត្រាចារ្យ នឹងក្រុមសិស្សនៃវិទ្យាល័យនេះនាំគ្នាធ្វើបុណ្យកឋិនរាល់ឆ្នាំ ឥតដែលខានសឹងមានពោលក្នុងសុន្ទរកថាដែលសិស្សឈ្មោះ ហ៊ុយ - នឹម សូត្រជាដំណាងសិស្សទាំងអស់នៅពេលធ្វើកឋិនទានក្នុងឆ្នាំ ១៩៥១ ដូចមានចុះជូនអ្នកអានតទៅនេះ :

## សុន្ទរកថា តំណាង

នៃសិស្សានុសិស្សវិទ្យាល័យស៊ីសុវត្ថិ ឆ្នាំ ១៩៥១

ហៅទៅវេរប្រគេនដល់ព្រះសង្ឃគង់នៅវត្តស្វាយដង្គំ ឃុំលេខ ៣ ក្រុងភ្នំពេញ

(ហ៊ុយ - នឹម : ជាអ្នកតែងនិងសូត្រ)

សូមក្រាបបង្គំទូល !

ទ្រង់ !

សូមជំរាបឯកឧត្តម !

នូវអស់លោក-អស់អ្នកសប្បុរសទាំងឡាយ ព្រមទាំងមិត្តគ្រប់គ្នា !

ពេលនេះជាកិត្តិយសមួយដ៏ប្រសើរពេណ្ណកាយ ចំពោះវិទ្យាល័យ-ស៊ីសុវត្ថិទាំងមូល ដោយបានទ្រង់, ឯកឧត្តម នឹងអស់លោកអស់អ្នកសប្បុរសជាពុទ្ធមាមកៈទាំងឡាយ ដែលទ្រង់សព្វព្រះរាជហឫទ័យសោមនស្ស យាងនឹងអញ្ជើញមកយ៉ាងឧឡារិក ជាអធិបតីនៃបុណ្យកឋិននេះ ។

ទូលព្រះបង្គំជាខ្ញុំ, ខ្ញុំបាទសូមថ្លែងអំណរដ៏ក្រៃលែងចំពោះទ្រង់ អស់លោក ក្នុងនាមនៃមិត្តរបស់ទូលព្រះបង្គំ ខ្ញុំបាទ នឹងក្នុងនាមនៃវិទ្យាល័យស៊ីសុវត្ថិ ដែលជាទីប្រជុំសិក្សាវិទ្យាសាស្ត្រក្នុងកម្ពុជរដ្ឋទាំងមូល ។

សូមទ្រង់ ឯកឧត្តម អស់លោក មេត្តាព្រះរាជទានទោស និងត្រាប្រណីដល់ទូលព្រះបង្គំ យើងខ្ញុំ ក្រែងមានខុសឆ្គាំឆ្គងត្រង់កិច្ចបដិសណ្ឋារៈ និងឋានវិទ្យាល័យចង្អៀតចង្អល់ តាំងក្នុងក៏ពុំសូវប្រពៃតាមព្រះរាជដ្ឋានៈ និងសមរម្យ ចំពោះទ្រង់, អស់លោក ។

បុព្វហេតុដើម ដែលអាចញុំាងកឋិនទានរបស់យើងខ្ញុំឲ្យពន្លកលូតលាស់ ដល់ផ្លោលផ្លឹក រុងរឿងយ៉ាងដូច្នេះ កើតឡើងដោយបំណងច្រើនយ៉ាង :

១ – ដោយយើងខ្ញុំ មានបំណងចង់រក្សាទំនៀមទំលាប់រៀមច្បងរបស់យើងខ្ញុំដែលតែងតែធ្វើបុណ្យនេះ រៀងរាល់ឆ្នាំជាយូរយារណាស់មកហើយ និងដើម្បីរក្សាប្រពៃណីរបស់ច្បាប់ព្រះពុទ្ធសាសនា ដែលធ្លាប់មានពិធីកឋិនទាន ក្រោយវេលាចេញព្រះវស្សា តាំងពីសម័យព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ ។

២ – ដោយយើងខ្ញុំមានគំនិតយល់ជាក់ច្បាស់ថា: ការធ្វើបុណ្យនេះជាកិច្ចមួយដ៏ប្រពៃចំពោះយើងខ្ញុំ ពីព្រោះពិធីបុណ្យក្នុងព្រះពុទ្ធ-សាសនាជាច្បាប់មួយ អាចទូន្មានប្រដៅដល់យើងខ្ញុំ ឲ្យមានសាមគ្គីធម៌ឲ្យចេះរួបរួមសន្តានចិត្ត មូលមិត្តនឹងគ្នាធ្វើការដោយមាំមួន ហើយអាចនឹងបង្រៀន ឲ្យយើងខ្ញុំចេះចាត់ចែងការតាំងពីនៅកុមារ រហូតដល់ចាស់ជរា ។

៣ — ដោយយើងខ្ញុំមានបំណងប៉ងនឹងរក្សាលទ្ធិព្រះពុទ្ធសាសនា ដែលជាសាសនាប្រៀនប្រដៅមនុស្សលោក ឲ្យចេះរាប់អានគ្នា ឲ្យចេះស្រឡាញ់គ្នា ឲ្យមានចិត្តស្លូតត្រង់មេត្តាករុណាគ្នា នឹងឲ្យមានសាមគ្គីធម៌ នេះហើយដែលជាកម្លាំងមួយយ៉ាងមាំ សំរាប់ដឹកនាំនឹងបំភ្លឺផ្លូវបណ្តាជន ដែលមានសញ្ជាតិជាមួយគ្នា ឲ្យធ្វើដំណើរទៅមុខបានស្រេះស្រួល មិនគុំគួនប្រកួតប្រណាំងទទឹងទាស់ខ្វែងគំនិតពីគ្នា មិនឲ្យបាក់បែកគ្នាឡើយ ។

ម្យ៉ាងទៀត ព្រះពុទ្ធសាសនា ដែលខេមរជនជាតិយើងរាប់អានគោរពប្រតិបត្តិសព្វថ្ងៃនេះ ពុំមែនមានប្រយោជន៍សំខាន់ ត្រឹមតែហុចផលទៅបរលោក សួគ៌ និព្វាន ប៉ុណ្ណោះទេ! អាចផ្តល់ប្រយោជន៍សំខាន់ៗ ជាច្រើនទៀតគឺ :

ជាឃ្លាំងសំដីភាសារបស់ខ្មែរ !

ជាឃ្លាំងច្បាប់ទំនៀមទំលាប់ខ្មែរ !

ជាឃ្លាំងវឌ្ឍនធម៌ទាំងពួង !

នឹងជាឃ្លាំងឧត្តមគតិរបស់ជាតិយើង !

មួយវិញទៀត អារ្យធម៌របស់ជាតិយើង ដែលមានសេសសល់ទៅបន្តិចបន្តួច មកដល់សព្វថ្ងៃនេះ ក្រោយដែលនៅក្រោមអំណាចឥទ្ធិពលរបស់ជាតិដទៃ អស់រយៈជាយូរអង្វែងឆ្នាំមកហើយនោះ គួរណាស់តែលេតលោយសាបសូន្យអស់លើងទៅហើយ ប៉ុន្តែដោយសារម្លប់នៃអារាម

អក្សរទាំងភាសាធម៌នោះ ក៏អាចដេកកោនគង់ជីវិតរស់ដល់មកសព្វថ្ងៃនេះ ។ ថ្វីបើនៅតាមផ្សារ តាមផ្លូវនៃទីក្រុងនានា គេឮស្នូរសព្ទតែសម្លេងភាសាជាតិដទៃ មានចិនយួនជាដើម ហើយនៅមន្ទីរធ្វើការខាងផ្លូវរាជការទាំងពួងគេឮស្នូរស័ព្ទសំដី និយាយជាភាសាបារាំង, តែគង់វត្តទាំងឡាយ នៅពេលធម្មតាក្តី បុរេលាបុណ្យទានក្តី ខ្មែរ និយាយទៅកាន់ខ្មែរ តែជាភាសាខ្មែរ ។

ទ្រង់ !

ឯកឧត្តម !

អស់លោក !

គង់ទ្រង់ជ្រាប បានជ្រាប បានឮខ្លះ អំពីជនជាតិយើងជាច្រើនពាន់នាក់ ដែលមានលំនៅក្នុងដែនកូសាំងស៊ីន នៅក្រោមអំណាចរដ្ឋាភិបាលរបស់ជាតិដទៃ ហើយនិយាយតែភាសាជាតិដទៃ ។ តើយើងអាចស្គាល់ជនអស់ទាំងនោះ ថាជាជាតិខ្មែរបានដែរឬទេ? បើប្រសិនណាជាយើងស្គាល់ តើយើងសំគាល់ដោយហេតុអ្វី? ដោយពិតគឺមានតែវត្តបាក់បែកដែលនៅសេសសល់ខ្លះនោះហើយជាគោលចារិក បង្ហាញជាភស្តុតាងយ៉ាងជាក់ច្បាស់ ថាជាខេមរជាតិពិត ៗ ។ ហេតុដូច្នោះហើយបានជាព្រះមហាចក្រពត្រាធិរាជព្រះនាមព្រះបាទ " ណាប៉ូលេអុងទី ១ " (Napoléon 1 ) ដែលជាមហាក្សត្រយ៉ាងឯកនៃប្រទេសបារាំងទ្រង់បាន

ចេញព្រះរាជឱង្ការថា : "សាសនា មានសណ្ឋានដូចត្រៃវិស័យ, ប្រទេសណាឥតសាសនា ប្រទេសនោះដូចជានាវាមួយ ដ៏ធំធេងឥតត្រៃវិស័យជាមគ្គុទ្ទេស" ។

ម្យ៉ាងទៀត ការដែលបង្ខំសន្ទានចិត្តរបស់ទូលព្រះបង្គំ, យើងខ្ញុំ ឲ្យផ្តួចផ្តើមធ្វើបុណ្យកឋិននេះ មិនមែនចំពោះតែតាមបំណងខាងលើនេះទេ គឺមានបំណងម្យ៉ាងទៀត ដ៏សំខាន់ :

"វត្តមង្គលវ័ន ស្វាយដង្គំ ជាបូជនីយស្ថានមួយឋិតនៅកៀនចន្លោះ ត្រង់កន្ទៀតផ្សារ នៃទីក្រុងភ្នំពេញ ឆ្ងាយដាច់អាល័យពីទីប្រជុំការសិក្សានានា មានសាលាបឋមសិក្សានិងវិទ្យាល័យជាដើម ។ កុមារតូចៗ របស់អ្នកក្រីក្រកំសត់ទុគ៌ត មានចំនួនរាប់រយនាក់ ច្រើនតែទៅនៅសំណាក់អាស្រ័យនឹងកុដិព្រះសង្ឃនាទីនោះ ដើម្បីនឹងស្វែងរកដំរេះវិជ្ជាអំពីលោក ។ ទូលព្រះបង្គំយើងខ្ញុំទាំងឡាយ យល់ឃើញជានិច្ចថា ធម្មតាសាលាបឋមសិក្សាខ្មែរ ដែលកើតឡើងក្នុងវត្តដោយសារលោក. សង្ឃ មិនសូវរឹងប៉ឹង មិនសូវមាំទាំ អាចនឹងធ្វើឲ្យកុមារទុគ៌តទាំងនោះ រៀនបានស្រួលប៉ុន្មានទេ ! ម្ល៉ោះហើយដំរេះវិជ្ជារបស់កុមារ ក៏រតែយឺតយូរមិនអាចនឹងធ្វើដំណើរទៅដោយរួសរាន់ ឲ្យឆាប់ហ័សទាន់សម័យនឹងគេឡើយ ច្រើនគ្រាន់តែរៀនបានចេះមើលអក្សរអាក់រអួល ហើយក៏បួសជាភិក្ខុសាមណេរទៅ ។ ព្រោះហេតុនេះហើយបានជាអ្នកចេះនៅស្រុកខ្មែរយើងមានចំនួនតិចណាស់ ។

ឱ! អាសូរជាតិខ្មែរល្ងង់ខ្លៅ! មេចក៏ដេកអ៊ុយតែយូរម៉្លេះ! បើខ្វះវិជ្ជាដូច្នេះតើបានសេចក្ដីសុខ សេចក្ដីចំរើនមកពីណាហ្ន៎, ព្រោះតាមមធុរភាសិតនៃស្រីហិតោបទេសរបស់លោក "អេឌូអារ្ដឡង់សារ៉ូ" (Edouard Lan Saro) ករបណ្ឌិតជាតិបារាំង ប្រែពីភាសាសំស្ក្រឹត លោកបានពោលទុកថា: "វិជ្ជានាំឲ្យបានវិន័យ, វិន័យនាំឲ្យកើតសេចក្ដីថ្លៃថ្នូរ, សេចក្ដីថ្លៃថ្នូរ នាំឲ្យបានទ្រព្យ, ទ្រព្យនាំឲ្យកើតធម៌, ធម៌នាំឲ្យបានសុខ" ។

ព្រោះហេតុនោះហើយ បានជាយើងខ្ញុំ ខំបែងចែករំលែកបច្ច័យនៃកឋិនទាននេះ ជា ២ ផ្នែក; ១ ផ្នែកសំរាប់បរិច្ចាគចំពោះការកសាងសាលាបឋមវិជ្ជាខ្មែរ ១ យ៉ាងគួរល្មម, ១ ផ្នែកទៀតវេរប្រគេនព្រះសង្ឃសំរាប់បំពេញការខ្វះខាតក្នុងកិច្ចកសាងសាលាបាលីក្ដី ជួសជុលព្រះវិហារក្ដី ឬ សង់កុដិក្ដី ។

ទ្រង់!

ឯកឧត្ដម!

អស់លោកទាំងឡាយ!

ព្រោះហេតុទាំងនោះហើយ បើទុកណា ជាយើងខ្ញុំមានជាប់ជំពាក់កន្ទុល បលិពោធទៅដោយករណីយកិច្ចយ៉ាងណា ឬ ក៏មានឧបសគ្គអ្វី មកឃាត់ឃាំង រាំងរាដល់យើងខ្ញុំយ៉ាងណាក៏ដោយ ក៏យើងខ្ញុំ

មានអំណត់ ខំស៊ូទ្រាំអត់ប្រមូលបញ្ចូលគំនិតបង្ហាប់គ្នាជាចិត្តមួយ លះសេចក្ដីកំណាញ់ ប្រឹងចំណាយបច្ច័យបន្តិចម្នាក់ៗ ដែលបានមកអំពីអំណោយរបស់មាតាបិតាយើងខ្ញុំ ក៏បានយកបច្ច័យនោះមករួមប្រមូលផ្សំផ្គុំផ្ដុំនឹងបច្ច័យរបស់ទ្រង់ ឯកឧត្ដម អស់លោក និងសប្បុរសទាំងឡាយ ស្ទើរតែគ្រប់ដំបន់ ឲ្យទាល់តែអង្គព្រះកឋិននេះ មានជីវិតលូតលាស់ដូច្នេះ ៗ ទូលព្រះបង្គំ យើងខ្ញុំ សូមទូលទ្រង់ និងជំរាបអស់លោកថា សូមទ្រង់, អស់លោក, តាំងព្រះរាជហឫទ័យ និងចិត្តសំគាល់ថា: អង្គព្រះកឋិននេះ ជារបស់ទ្រង់, ឯកឧត្ដម និងអស់លោក-អ្នកពិតៗ ។

នៅវេលាម៉ោង ៨ ព្រឹកថ្ងៃអាទិត្យស្អែកនេះ យើងខ្ញុំនឹងរៀបក្បួនដង្ហែកឋិនទាន ទៅវេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តមង្គលវ័ន (ស្វាយដង្គំ) ឃុំលេខ ៣ ក្រុងភ្នំពេញ ៗ សូមអញ្ជើញទ្រង់ ឯកឧត្ដម អស់លោក យាងនិងអញ្ជើញមកជួយហែអង្គព្រះកឋិន នៃយើងខ្ញុំដើម្បីនឹងលើក ដំកើង កិត្តិស័ព្ទ នៃពិធីបុណ្យនេះ ឲ្យបានជាឧឡារិកអឺក-កធឹក ឈូឆរល្អដូច្នេះទៀត ។

នៅអវសាន ទូលព្រះបង្គំ, យើងខ្ញុំ សូមលើកហត្ថាបួងសួងដល់ព្រះមហាទេព ដ៏មានបុណ្យ ជាចមអមរនិករ ប្រសិទ្ធពរបវរសួស្ដី :

១ — ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលជាកំពូលនឹងម្លប់ត្រជាក់ របស់ពលរដ្ឋខ្មែរ ព្រមទាំងព្រះរាជវង្សានុវង្ស ៗ

២ - ថ្វាយចំពោះព្រះពុទ្ធសាសនា សូមឲ្យឋិតថេរថេរកាលតទៅ

៣ - ដល់កម្ពុជរដ្ឋ សូមឲ្យប្រទេសខ្មែរ មានអនាគតរុងរឿងចំរុងចំរើន បញ្ចាំងរស្មីត្រចះត្រចង់ ទៅលើសព្វដំបន់គង់សកលលោក នឹងឲ្យបានសម្បូរទៅដោយសន្តិសុខ, អារ្យធម៌ នឹងវប្បធម៌គ្រប់យ៉ាង ។

ក្រោយបង្អស់គឺបច្ឆិមពាក្យ មុននឹងបញ្ចប់នូវសុន្ទរកថានេះ ទូលព្រះបង្គំ, យើងខ្ញុំ សូមឧទ្ទិសកុសលផល ជូនចំពោះបុគ្គលការដែលមានគុណលើសលប់, ចំពោះឯកឧត្តម, អស់លោក, អស់អ្នកសប្បុរសជាពុទ្ធមាមកៈ នឹងមិត្តភក្តិទាំងឡាយ ឲ្យប្រកបទៅដោយសេចក្តីសុខសេចក្តីចំរើន គ្រប់ប្រការដោយផលានិសង្សនៃកឋិនទានទេះ ចុះ ។

វិទ្យាល័យ ស៊ីសុវត្ថិ ថ្ងៃ២៧ តុលា គ. ស. ១៩៥១

ហ៊ុយ-នឹម និស្សិត ថ្នាក់ទី ២ ទំនើប